00242969

C401511

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស |
| **ឈ្មោះសំណុំរឿង:** | **ខៀវ សំផន** |
| **ដាក់តម្កល់ជូន:** | អង្គបុរេជំនុំជម្រះ |
| **កាលបរិច្ឆេទដាក់ឯកសារ:** | ២៧ វិច្ឆិកា ២០០៨ |
| **ភាគីអ្នកតម្កល់:** | ក្រុមការពារក្តី |
| **ភាសា:** | ភាសាដើមជាភាសាបារាំង (បកប្រែក្រៅផ្លូវការជាភាសាខ្មែរ) |
| **ប្រភេទឯកសារ:** | **សាធារណៈ** |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 11 / 2008
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: [signature]

---

# សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធការដោះលែងឲ្យមានសេរីភាព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨

---

<u>បញ្ជូនដោយ:</u>

**មេធាវីរបស់លោក ខៀវ សំផន**

លោក ស សូវ៉ាន

លោក Jacques VERGÈS

<u>ជំនួយការ:</u>

អ្នកស្រី សេង សុជាតា

កញ្ញា Charlotte MOREAU

<u>បញ្ជូនទៅ:</u>

**ចៅក្រមអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន៍យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**ការិយាល័យសហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 01 / 12 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# ជូនចំពោះអង្គបុរេជំនុំជម្រះ

## I. សេចក្តីផ្តើម

1. តាមរយៈដីកាសម្រេចចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត (ស.ច.ស) បានបដិសេធសំណើជាបន្ទាន់សុំដោះលែងឲ្យមានសេរីភាពដែល លោក ខៀវ សំផន បានដាក់នៅថ្ងៃទី ៨ តុលា ២០០៨[1]។ ដោយអនុលោមតាមវិធាន ៧៥ នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្តីបានប្រកាសអំពីគោលបំណងរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាខាងលើនេះ នៅថ្ងៃទី៤ វិច្ឆិកា ២០០៨[2]។

2. ដោយអនុលោមតាមមាត្រា ៨.២ នៃសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ឯកសារ និងដោយឈរលើមូលដ្ឋាននៃវិធាន ៦៤.២ និង ៧៤.៣ (ច) នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្តីសូមដាក់សារណាបណ្តឹងឧទ្ធរណ៍នេះ នៅថ្ងៃនេះ។

## II. សេចក្តីសង្ខេបអំណះអំណាង

### ១) សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត គឺប្រឡាក់ប្រឡូសដោយ*កំហុសផ្នែកច្បាប់*

3. ដោយបដិសេធមិនពិនិត្យពិចារណាលើកាលៈទេសៈទាំងអស់នៃមូលហេតុ និងអត្ថិភាពនៃវិធានការដំណោះស្រាយចំពោះការដោះលែងឲ្យមានសេរីភាព សហចៅក្រមស៊ើបអង្កេតបានធ្វើការបកស្រាយដោយភ័ន្តច្រឡំ ទៅលើអត្ថបទច្បាប់អនុវត្ត ទាក់ទងនឹងការដោះលែងឲ្យមានសេរីភាពវិញ។ ថ្វីបើមើលពីខាងក្រៅទៅហាក់បីដូចជាទំនង ប៉ុន្តែសេចក្តីសម្រេចរបស់សហចៅក្រម គឺឈរលើមូលដ្ឋាននៃភាពធ្ងន់ធ្ងរនៃអង្គហេតុដែលបានចោទប្រកាន់ចំពោះលោក ខៀវ សំផន តែប៉ុណ្ណោះ។

### ២) សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត គឺប្រឡាក់ប្រឡូសដោយ*កំហុសផ្នែកអង្គហេតុ*

4. សហចៅក្រមស៊ើបអង្កេតចាត់ទុកថា ពុំមានវិធានការណ៍ត្រួតពិនិត្យផ្នែកតុលាការណាមួយអាចធានាបាននូវការទទួលបានតម្រូវការខាងលើប្រកបដោយប្រសិទ្ធភាពនោះទេ ទោះបីជាវិធានការនោះមានភាពម៉ឺងម៉ាត់យ៉ាងណាក៏ដោយ។ ប៉ុន្តែ អ្វីៗដែលសហចៅក្រមស៊ើបអង្កេតលើកឡើង

[1] ដីកាបដិសេធការដោះលែងឲ្យមានសេរីភាព ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C40/4*

[2] សៀវភៅចុះបណ្តឹងឧទ្ធរណ៍ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ C40/5*

ដើម្បីគាំទ្រអំណះអំណាងនេះ គឺមិនសមហេតុសមផលដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃការកត់សម្គាល់មួយបែបនេះទេ។

**៣) ការដោះលែងឲ្យមានសេរីភាពគឺជាសេចក្តីសម្រេចដ៏ត្រឹមត្រូវតែមួយគត់ នៅក្នុងរឿងក្តីនេះ**

5. តាមការពិត ការដោះលែងឲ្យមានសេរីភាពគឺជាវិធានការណ៍ដ៏ចាំបាច់និងត្រឹមត្រូវតែមួយគត់ នៅក្នុងកាលៈទេសៈទាំងអស់នៃមូលហេតុនេះ។

## III. អង្គហេតុ និង នីតិវិធី ដែលកំពុងប្រព្រឹត្តទៅ

### ក. អង្គហេតុ

6. អស់រយៈពេលជាងមួយឆ្នាំហើយ ដែលលោក ខៀវ សំផន ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះ «បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (អំពើមនុស្សឃាត ការសម្លាប់បំផុតពូជ ការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដ៏ទៃទៀត) និងឧក្រិដ្ឋកម្មសង្គ្រាម ដែលផ្អែកលើការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ឆ្នាំ១៩៤៩ (អំពើមនុស្សឃាតដោយចេតនា ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើឲ្យឈឺចាប់ខ្លាំងដោយចេតនា ដល់រាងកាយ និងសុខភាព ការដកហូតដោយចេតនាពីអ្នកទោសសង្គ្រាម និងជនស៊ីវិល នូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ការនិរទេស ឬជន្លៀស ឬការបង្ខាំងជនស៊ីវិលដោយខុសច្បាប់) »។”[3]

7. អស់រយៈពេលជាងមួយឆ្នាំហើយ ដែលលោក ខៀវ សំផន ត្រូវបានឃុំខ្លួន ដោយសារ « តាមរយៈឯកសារ និងចម្លើយសាក្សីជាច្រើនដែលមានក្នុងសំណុំរឿង» សចស បានយល់ឃើញថា មានហេតុផលនានាដែលអាចឲ្យជឿជាក់ថា លោក ខៀវ សំផន បានប្រព្រឹត្តនូវបទល្មើសដូចដែលបានដាក់បន្ទុកមែន។[4]

8. ប៉ុន្តែ អស់រយៈពេលជាងមួយឆ្នាំហើយ ដែលលោក ខៀវ សំផន ពុំអាចការពារខ្លួនឯងបាន។ លោក VERGÈS សហមេធាវីអន្តរជាតិដែលត្រូវបានជ្រើសតាំងមកការពារក្តីឲ្យគាត់ ពុំអាចពិនិត្យមើលសំណុំរឿងស៊ើបអង្កេត ជាភាសាដែលគាត់អាចយល់បាននោះឡើយ។ ដូច្នេះ ក្រុមការពារក្តីរបស់លោក ខៀវ សំផន ត្រូវបានកាត់ផ្តាច់ និងមិនអាចចូលរួមក្នុងនីតិវិធី ស្របតាមលក្ខខណ្ឌសម្រាប់ការកាត់ក្តីដោយត្រឹមត្រូវបានឡើយ។

---

[3] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ *ឯកសារតុលាការ C26* កថាខណ្ឌ ៥

[4] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ *ឯកសារតុលាការ C26*

9. ក្រុមការពារក្តីយល់ឃើញថា នៅចុងបញ្ចប់នៃនីតិវិធីដែលបានប្រព្រឹត្តិទៅចំពោះ "កំហុសផ្នែកនីតិវិធី" នៅចំពោះមុខអង្គបុរេជំនុំជម្រះ លោក ខៀវ សំផន នឹងត្រូវបានដោះលែងឲ្យមានសេរីភាព។ ដូច្នេះ ដើម្បីជៀសវាងការបន្តចាត់វិធានការណ៍ដែលរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់ជនត្រូវចោទ (ព្រោះថាជាវិធានការណ៍ដែលធ្វើឡើងតាមតែអំពើចិត្ត[5]) ដែលទោះជាយ៉ាងណាក៏ដោយ គឺមិនមានភាពចាំបាច់នោះ ក្រុមការពារក្តីសូមស្នើទៅសហចៅក្រមស៊ើបអង្កេតឲ្យបង្គាប់ឲ្យមានការដោះលែងលោក ខៀវ សំផន ឲ្យមានសេរីភាពវិញ នៅក្នុងលក្ខខណ្ឌដែលខ្លួនយល់ឃើញថាមានលក្ខណៈសមស្រប។

10. សហចៅក្រមស៊ើបអង្កេតបានបដិសេធ៖ ប៉ុន្តែនេះគឺជាសេចក្តីសម្រេចមួយដែលមិនមានលក្ខណៈត្រឹមត្រូវ ហើយដែលគ្រាន់តែឈរលើមូលដ្ឋាននៃភាពធ្ងន់ធ្ងរនៃអង្គហេតុដែលបានចោទប្រកាន់តែប៉ុណ្ណោះ។ ដូច្នេះ តួនាទីរបស់ខ្លួនគឺមានលក្ខណៈជានិមិត្តរូបសុទ្ធសាធ និងមានមូលដ្ឋានខុសច្បាប់។

## ខ. នីតិវិធី

11. អស់រយៈពេលជិតមួយឆ្នាំមកហើយដែលសហមេធាវីការពារក្តីប៉ុនប៉ងធ្វើឲ្យមានសុពលភាព នូវសិទ្ធិដាច់ខាត និងដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់លោក ខៀវ សំផន ចំពោះការការពារខ្លួនដ៏ពិតប្រាកដមួយ។

12. នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៨ លោក VERGÈS បានស្នើជាបឋមទៅសហចៅក្រមស៊ើបអង្កេតឲ្យបង្គាប់ឲ្យធ្វើការបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ដោយគូសបញ្ជាក់ថា គាត់មិនអាចការពារកូនក្តីរបស់ខ្លួនបានទេ បើមិនអាចពិនិត្យឯកសារសំណុំរឿងព្រហ្មទណ្ឌបានដោយពិតប្រាកដបានឡើយ។[6]

---

[5] ទាក់ទងនឹងចំណុចនេះ សហមេធាវីការពារក្តីសូមឲ្យអង្គបុរេជំនុំជម្រះ ពិនិត្យអំណះអំណាងដែលខ្លួនបានលើកឡើង ដើម្បីគាំទ្រចំពោះការជំទាស់របស់ខ្លួនឲលើការបន្តការឃុំខ្លួន (ការជំទាស់របស់ក្រុមការពារក្តីទាក់ទងនឹងការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/3* កថាខណ្ឌ ១៩ ដល់ ២៨។

[6] រឿងក្តី ខៀវ សំផន "កំណត់ហេតុសាកសួរចម្លើយ" *ឯកសារតុលាការ D75*

13. បន្ទាប់មកទៀត នៅថ្ងៃទី២៣ មេសា ២០០៨ ក្រុមការពារក្តីបានលើកឡើងអំពីការរំលោភបំពាននេះ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងសវនាការបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។[7]

14. នៅទីបញ្ចប់ គឺនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ បន្ទាប់ពីការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបង្គាប់ឲ្យមានការបកប្រែឯកសារសំណុំរឿង[8] ក្រុមការពារក្តីបានស្នើទៅអង្គបុរេជំនុំជម្រះឲ្យកត់សម្គាល់អំពីការរំលោភសិទ្ធិរបស់ក្រុមការពារក្តី ដែលបណ្តាលមកពីសេចក្តីសម្រេចខាងលើនេះ ហើយពីអវត្តមាននៃការបកប្រែ ឲ្យបង្គាប់ឲ្យដោះលែងលោក ខៀវ សំផន ឲ្យមានសេរីភាព ដោយសារតែកំហុសផ្នែកនីតិវិធី[9]។

15. នៅថ្ងៃទី២១ សីហា ២០០៨ តាមការបង្គាប់របស់អង្គបុរេជំនុំជម្រះ ក្រុមមេធាវីការពារក្តីបានបញ្ជាក់ឡើងវិញជាថ្មីអំពីគោលជំហររបស់ខ្លួនលើបញ្ហានេះ[10]។ ក៏ប៉ុន្តែ អង្គបុរេជំនុំជម្រះបែរជាយល់ឃើញថា គោលជំហរនេះមិនជំទាស់ទៅនឹងការសម្រេចសេចក្តីលើនីត្យានុកូលភាពនៃការឃុំខ្លួនឡើយ[11]។

16. ដោយហេតុដូច្នេះ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ ក្រុមការពារក្តីត្រូវបង្ខំចិត្តដកបណ្តឹងឧទ្ធរណ៍នេះ[12] ហើយនៅក្នុងពេលជាមួយគ្នានោះ បានស្នើទៅសហចៅក្រមស៊ើបអង្កេតឲ្យបង្គាប់ឲ្យដោះលែងលោក ខៀវ សំផន ឲ្យមានសេរីភាព[13]។ សំណើនេះត្រូវបានបដិសេធដោយសេចក្តីសម្រេចចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨[14]។

---

[7] កំណត់ហេតុសវនាការថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/26*

[8] សម្ងាត់ កំណត់ហេតុសវនាការថ្ងៃទី២៣ ខែមេសា ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/25*

[9] សារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី ប្រឆាំងនឹងការបដិសេធសំណើសុំបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ *ឯកសារតុលាការ A190/I/1*

[10] សេចក្តីជូនដំណឹងអំពីគោលជំហររបស់ក្រុមការពារក្តីទៅអង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/28*

[11] សេចក្តីបង្គាប់ទៅក្រុមការពារក្តីទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១៥ សីហា ២០០៨ *ឯកសារតុលាការ C26/I/27*

[12] សេចក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/30*

[13] សំណើសុំជាបន្ទាន់ឲ្យដោះលែងឲ្យមានសេរីភាព ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C40*

[14] ដីកាសម្រេចបដិសេធការដោះលែងឲ្យមានសេរីភាព ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C40/2*

17. នៅថ្ងៃទី៣១ តុលា ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងមកសហមេធាវីការពារក្ដីអំពីគោលបំណងរបស់ខ្លួនក្នុងការបន្តការឃុំខ្លួនបណ្ដោះអាសន្ន សម្រាប់រយៈពេលមួយឆ្នាំទៀត[15]។
18. នៅថ្ងៃទី៤ វិច្ឆិកា ២០០៨ ក្រុមការពារក្ដីបានជូនដំណឹងអំពីគោលបំណងរបស់ខ្លួន ក្នុងការប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចបដិសេធការដោះលែងឲ្យមានសេរីភាព[16]។
19. នៅថ្ងៃទី១៨ វិច្ឆិកា ២០០៨ ទោះបីជាមានការជំទាស់ដែលដាក់ដោយក្រុមការពារក្ដីក៏ដោយ[17] ក៏សហចៅក្រមស៊ើបអង្កេតនៅតែចាត់ទុកថា ការបន្តការឃុំខ្លួនមានលក្ខណៈត្រឹមត្រូវដែរ[18]។ ក្រុមការពារក្ដីប្រឆាំងជំទាស់នឹងការបន្តការឃុំខ្លួននេះ ហើយក៏បានជូនដំណឹងអំពីសេចក្ដីប្រកាសប្ដឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងសេចក្ដីសម្រេចនេះ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨[19]។
20. សារណានេះ ដែលបានដាក់នៅថ្ងៃទី២៧ ខែវិច្ឆិកា គឺមានរយៈពេលចំនួន ៩ ថ្ងៃ បន្ទាប់ពីសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការបន្តការឃុំខ្លួនសម្រាប់រយៈពេលមួយឆ្នាំទៀត នឹងមិននិយាយអំពីកាលៈទេសៈថ្មីនេះទេ ហើយនឹងដាក់ការទាញអំណះអំណាងរបស់ខ្លួន នៅកាលបរិច្ឆេទនៃសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ពោលគឺរយៈពេលប្រហែលមួយខែ នៅមុនការផុតកំណត់លិខិតឃុំខ្លួន។

## IV. ការរំឭកអំពីច្បាប់អនុវត្ត

21. បទបញ្ញត្តិសំខាន់ៗ និងទាក់ទងនឹងនីតិវិធីដែលគាំទ្របណ្ដឹងឧទ្ធរណ៍នេះ ត្រូវបានលើកឡើងរួចមកហើយនៅក្នុងសំណើសុំលើកដំបូងនិងជាបន្ទាន់ នៃការសុំដោះលែងឲ្យមានសេរីភាពរបស់ក្រុមការពារក្ដី។ ដូច្នេះ ក្រុមការពារក្ដីសូមស្នើទៅអង្គបុរេជំនុំជម្រះឲ្យពិនិត្យមើលពីកថាខណ្ឌទី១០ ដល់ទី១៧ នៃសំណើសុំនេះ ដើម្បីពិចារណាអំពីបទបញ្ញត្តិដែលខ្លួនយកមកធ្វើជាអំណះអំណាងនេះ[20]។
22. ប៉ុន្តែ ក្រុមការពារក្ដីសូមរំឭកថា សិទ្ធិទទួលបានសេរីភាពគឺជាសេរីភាពជាមូលដ្ឋានដែលមានចែងនៅក្នុងមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមការពារក្ដីក៏សូមរំឭកផងដែរថា

---

[15] សេចក្ដីជូនដំណឹង (វិធាន ៦៣.៧) *ឯកសារតុលាការ C26/2*

[16] សៀវភៅចុះបណ្ដឹងឧទ្ធរណ៍ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ C40/5*

[17] ការកត់សម្គាល់របស់ក្រុមការពារក្ដី លើការបន្តការឃុំខ្លួនបណ្ដោះអាសន្ន ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/3*

[18] ដីកាសម្រេចបន្តការឃុំខ្លួនបណ្ដោះអាសន្ន ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/4*

[19] សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ វិច្ឆិកា ២០០៨ *ឯកសារតុលាការ C26/5*

[20] សំណើសុំជាបន្ទាន់ឲ្យដោះលែងឲ្យមានសេរីភាពវិញ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C40*

ដោយអនុលោមតាមមាត្រា ១០៩ នៃរដ្ឋធម្មនុញ្ញ អំណាចតុលាការ គឺជាអ្នកធានា និងអ្នកការពារនូវសេរីភាពនេះ។

## V. អំណះអំណាង

### ក. សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតគឺប្រឡាក់ប្រឡូសទៅដោយកំហុសផ្នែកច្បាប់

23. សហចៅក្រមស៊ើបអង្កេតបានសម្រេចជំទាស់នឹងការដោះលែងឲ្យមានសេរីភាព ដោយមិនគិតគូរពិចារណាអំពីកាលៈទេសៈទាំងអស់នៃមូលហេតុទេ ហើយបានធ្វើយុត្តិកម្មសេចក្តីសម្រេចរបស់ខ្លួនដោយគ្រាន់តែឈរលើមូលដ្ឋាននៃភាពធ្ងន់ធ្ងរនៃអង្គហេតុ ដែលខ្លួនទទួលបន្ទុកស៊ើបអង្កេតតែប៉ុណ្ណោះ។ ការបកស្រាយនេះ គឺផ្ទុយទៅនឹងច្បាប់អនុវត្ត។

១) <u>សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតមិនមានភាពត្រឹមត្រូវទេ បើយោងតាមកាលៈទេសៈទាំងមូលនៃមូលហេតុ</u>

24. ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព[21]។ ដូច្នេះ នៅក្នុងករណី (ដែលត្រូវស្ថិតនៅជាអញ្ញត្រកម្ម) ដែលជនត្រូវចោទត្រូវបានឃុំខ្លួននោះ សហចៅក្រមស៊ើបអង្កេតអាចបង្គាប់ឲ្យដោះលែង“បានគ្រប់ពេលវេលា” ប្រសិនបើជនត្រូវចោទធ្វើការស្នើសុំ[22]។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា នេះហើយជាហេតុផលដែលថា មានតែសេចក្តីសម្រេចបដិសេធដោះលែងឲ្យមានសេរីភាពតែមួយគត់ដែលត្រូវតែមានសម្អាងហេតុច្បាស់លាស់។

25. ដើម្បីឲ្យសេចក្តីសម្រេចបដិសេធមួយមានមូលដ្ឋាន អង្គជំនុំជម្រះដែលមានសមត្ថកិច្ចត្រូវបញ្ជាក់មូលហេតុលម្អិតច្បាស់លាស់ ពិនិត្យពិចារណាទៅលើកាលៈទេសៈទាំងអស់នៃរឿងក្តី ហើយនិងត្រូវផ្តល់ជាគំនិតមួយដោយមានអំណះអំណាងអំពីរឿងនេះ[23]។

---

[21] មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបញ្ជាក់យ៉ាងច្បាស់អំពីចំណុចនេះ ហើយប្រសិនបើសច្ចធារណ៍នេះមិនត្រូវបានគេដាក់បញ្ចូលជាផ្លូវការទៅក្នុងវិធាននផ្ទៃក្នុងរបស់អ.វ.ត.ក នៅក្នុងឱកាសនៃសម័យប្រជុំពេញអង្គនោះ គឺក៏ពីព្រោះតែអារម្មណ៍ជាទូទៅយល់ថា វាមិនមានប្រយោជន៍ក្នុងការលើកឡើងអំពីភាពជាក់ស្តែងមួយបែបនេះ។

[22] វិធាន ៦៤(២) នៃវិធានផ្ទៃក្នុង និងមាត្រា ២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

[23] រដ្ឋអាជ្ញា *c. Lukic*, IT-98-32/1-AR65.1, ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០៧ សេចក្តីសម្រេចទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីសំណើសុំដោះលែង *Sredoje Lukic* ឲ្យមានសេរីភាពជាបណ្តោះអាសន្ន (សេចក្តីបកប្រែក្រៅផ្លូវការ) កថាខណ្ឌ ៧។

26. ជាការពិត . នៅពេលដែលសហចៅក្រមស៊ើបអង្កេតមានអំណាចឆន្ទានុសិទ្ធ ដើម្បីយល់ព្រមដោះលែងឲ្យមានសេរីភាពនោះ អំណាចរបស់ខ្លួនត្រូវបានចងភ្ជាប់នៅពេលដែលខ្លួនដាក់ការបដិសេធរបស់ខ្លួនជំទាស់នឹងជនត្រូវចោទ។ ជាការពិត រាល់ការដាក់កម្រិតចំពោះសិទ្ធិ ឬសេរីភាពរបស់ជនត្រូវចោទត្រូវតែមាន"លក្ខណៈចាំបាច់"ផង និង"មានសមាត្រ"ទៅនឹងកាលៈទេសៈផង[24]។ ដូច្នេះ ដើម្បីសម្រេចបញ្ជាក់អះអាងអំពីភាពស្របច្បាប់នៃការឃុំខ្លួន និងបដិសេធការដោះលែងឲ្យមានសេរីភាព គឺមិនត្រឹមតែត្រូវមានហេតុផលពិសេសៗដែលបញ្ជាក់អំពីភាពត្រឹមត្រូវនៃការឃុំខ្លួនប៉ុណ្ណោះទេ ប៉ុន្តែការដកហូតសេរីភាពត្រូវតែមានភាពចាំបាច់ទៀតផង។ ហើយការដកហូតសេរីភាពនេះថែមទាំងត្រូវតែជាវិធានការណ៍សមហេតុផលតែមួយគត់នៅក្នុងកាលៈទេសៈនៃមូលហេតុ[25]។ ប្រសិនបើអាចមានវិធានការណ៍មួយផ្សេងទៀតដែលមិនសូវដាក់កម្រិតចំពោះសិទ្ធិរបស់ជនត្រូវចោទអាចធ្វើឡើងបាននោះ គឺត្រូវតែអនុម័តយកវិធានការណ៍នោះ[26]។

27. នៅក្នុងរឿងក្តីនេះ សហចៅក្រមស៊ើបអង្កេតធ្វើមិនដឹងមិនឮទាល់តែសោះចំពោះកាលៈទេសៈដែលកើតមាន។ សំណើសុំឲ្យដោះលែងលោក ខៀវ សំផន ឲ្យមានសេរីភាពជាបន្ទាន់បានធ្វើឡើងនៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ បន្ទាប់ពីការដកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន។ សំណើនេះមិនមែនជាសំណើសុំដោះលែងឲ្យមានសេរីភាពធម្មតានោះទេ ប៉ុន្តែគឺជាសំណើបន្ទាន់ដើម្បីរក្សាបាននូវសិទ្ធិរបស់ជនត្រូវចោទ។

28. ជាការពិត សំណើនេះស្ថិតនៅក្នុងបរិបទនៃនីតិវិធីដ៏ពិសេសមួយ៖ គឺជាបរិបទនៃនីតិវិធីដែលបានធ្វើឡើងដោយសារមានកំហុសផ្នែកនីតិវិធី ដោយមូលហេតុមានការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិ

---

[24] សូមអានជាឧទាហរណ៍៖ CPI *រដ្ឋអាជ្ញា c. Germain Katanga និង Mathieu Ngudjolo Chui* ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៨ ICC-01/04-01/07 សេចក្តីសម្រេចដែលដកចេញនូវការហាមឃាត់ការទាក់ទង និងការឆ្លើយឆ្លងគ្នារវាង Germain Katanga និង Mathieu Ngudjolo Chui ជាពិសេសនៅកថាខណ្ឌ ៩។

[25] សូមអានសេចក្តីកត់សម្គាល់របស់ប្រធាន នៅក្នុងរឿងក្តី *Jokić* (កំណត់ហេតុសវនាការ តុលាការអន្តរជាតិយូហ្គោស្លាវី ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០២ *រដ្ឋអាជ្ញា c. Jokic* IT-02-60, p. 42-43)៖ "នៅក្នុងច្បាប់ព្រហ្មទណ្ឌក៏ដូចជានៅក្នុងច្បាប់អន្តរជាតិ វិធានការណ៍មួយមានលក្ខណៈសមាមាត្រ តែប្រសិនបើវាមានលក្ខណៈសមរម្យប៉ុណ្ណោះ។ ឬទីពីរ មានលក្ខណៈ ចាំបាច់។ ទីបី ប្រសិនបើកម្រិតនិងទំហំរបស់វាមានទំនាក់ទំនងជាមួយនឹង គោលដៅដែលបានធ្វើ"។

[26] TPIY *រដ្ឋអាជ្ញា c. Hadžihasanović និង Kubura* សេចក្តីសម្រេចយល់ព្រមផ្តល់ការដោះលែងឲ្យមានសេរីភាពជាបណ្តោះអាសន្នដល់ Amir Kubura, IT-01-47-PT ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ កថាខណ្ឌ ៨។ នៅត្រង់ចំណុចនេះ សូមអានការលើកឡើងនូវគំនិតដើម្បីគាំទ្រសំណើបន្ទាន់សុំដោះលែងឲ្យមានសេរីភាព (សំណើបន្ទាន់សុំដោះលែងឲ្យមានសេរីភាព ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C40 ជាពិសេសពីកថាខណ្ឌទី១៨ ដល់ ២៤*)។

របស់ក្រុមការពារក្ដី .ទៅលើសវនាការបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្នដែលបានពន្យារពេលលើសពីប្រាំពីរខែ ហើយនៅទីបញ្ចប់ត្រូវបានទុកជាមោឃៈ និងទៅលើក្រុមការពារក្ដីមួយដែលលែងជាក្រុមការពារក្ដីទៀតហើយ[27]។

29. សហចៅក្រមស៊ើបអង្កេតបានធ្វើមិនដឹងមិនឮទាំងស្រុងចំពោះបរិបទនេះ។ ប៉ុន្តែ ប្រសិនបើវាជាការពិតដែលគ្មានអ្វីមួយតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតផ្លាស់ប្ដូរសេចក្ដីសម្រេចរបស់ខ្លួន ទាក់ទងនឹងបញ្ហានៃការបកប្រែនោះ[28] សំណើសុំដោះលែងលោក ខៀវ សំផន ដាក់កម្ហិតឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការពិចារណា "ទៅតាមកាលៈទេសៈទាំងមូលនៃមូលហេតុ"។

30. បញ្ហានៃការបកប្រែបង្កឱ្យមានបញ្ហាដ៏ធ្ងន់ធ្ងរបំផុតទាក់ទងនឹងនីត្យានុកូលភាព និងភាពស្របច្បាប់របស់ជនត្រូវចោទ ខៀវ សំផន[29]។ អង្គបុរេជំនុំជម្រះបានទទួលស្គាល់អំពីបញ្ហានេះ ហើយបានបញ្ជាក់អះអាងថា ការជជែកពិភាក្សាតទល់នៅក្នុងសវនាការជាសាធារណៈគឺមានភាពត្រឹមត្រូវទាក់ទងនឹងបញ្ហាមួយបែបនេះ ដោយហេតុថាបញ្ហានេះធ្វើឱ្យប៉ះពាល់ដល់ភាពយុត្តិធម៌នៃរឿងក្ដី[30]។ សហមេធាវីការពារក្ដីបានលើកឡើងយ៉ាងច្បាស់លាស់អំពីការណ៍ដែលខ្លួនលែងអាចការពារកូនក្ដីរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាពទៀតហើយ ហើយខ្លួនចាត់ទុកនីតិវិធីថាខុសច្បាប់ និងជាជាក់ស្ដែង ចាត់ទុកការឃុំខ្លួនបណ្ដោះអាសន្នថាជាការឃុំខ្លួនដែលធ្វើឡើងស្រេចតែនឹងអំពើចិត្ត។

---

[27] ក្រុមការពារក្ដីនឹងលែងបញ្ជាក់លម្អិតហើយ នៅមុនបរិបទដែលសហចៅក្រមស៊ើបអង្កេតបានសម្រេចលើសំណើសុំដោះលែងឱ្យមានសេរីភាពជាបន្ទាន់របស់ក្រុមការពារក្ដី។ ក្រុមការពារក្ដីសូមស្នើទៅអង្គបុរេជំនុំជម្រះ ឱ្យពិនិត្យមើលចំណុចនេះពីកថាខណ្ឌ ២ ដល់ ៩ នៃសំណើសុំរបស់ខ្លួន។ (សំណើបន្ទាន់សុំដោះលែងឱ្យមានសេរីភាព ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ ឯកសារតុលាការ *C40*)។

[28] ជាការពិត តាមរយៈដីកាចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ (ដីកាស្ដីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីនីមួយៗទាក់ទងនឹងការបកប្រែ *ឯកសារតុលាការ A196)* សហចៅក្រមស៊ើបអង្កេតបានចាត់ទុកថា ការបកប្រែទាំងស្រុងនូវឯកសារសំណុំរឿងស៊ើបអង្កេតលែងអាចធ្វើឡើងនៅក្នុងរយៈពេលមួយសមស្របទៀតហើយ ហើយដោយហេតុដូច្នេះ ការបកប្រែនេះលែងចាំបាច់សម្រាប់ធានាបាននូវការជួយសង្គ្រោះសិទ្ធិរបស់ជនត្រូវចោទទៀតហើយ ហើយជាពិសេសនោះគឺសម្រាប់សិទ្ធិរបស់ជនត្រូវចោទដែលត្រូវទទួលបានការជំនុំជម្រះនៅក្នុងរយៈពេលមួយសមស្រប និងភាពយុត្តិធម៌នៃរឿងក្ដី។ (ដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗទាក់ទងនឹងការបកប្រែ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ *ឯកសារតុលាការ A190)*។

[29] ការរំលោភ និងផលវិបាកទាំងអស់ដែលបណ្ដាលមកពីបញ្ហានេះ ទាក់ទងនឹងនីត្យានុកូលភាពនៃនីតិវិធី និងការឃុំខ្លួន ត្រូវបានលើកឡើងដើម្បីគាំទ្រដល់បណ្ដឹងឧទ្ធរណ៍របស់ក្រុមការពារក្ដី ប្រឆាំងនឹងការបដិសេធសំណើសុំបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌ ("សារណារបស់ក្រុមការពារក្ដីស្ដីពីការបកប្រែ" ពីកថាខណ្ឌទី២៨ ដល់ ៥៤ ៥៥ ដល់ ៧១ និងពី ៧២ ដល់ ៧៩)។

[30] សេចក្ដីសម្រេចទាក់ទងនឹងពាក្យសុំរបស់ ខៀវ សំផន ដែលស្នើឱ្យមានការប្រព្រឹត្តទៅនូវសវនាការជាសាធារណៈមួយ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ A190/I/8* កថាខណ្ឌ ៨។

31. ទាក់ទងនឹងនីតិវិធី បញ្ហានៃការបកប្រែបាននាំឲ្យឈានទៅដល់ការលើកពេលសវនាការបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន។ អង្គបុរេជំនុំជម្រះយល់ឃើញថា លោក VERGÈS គឺជាអ្នកទទួលខុសត្រូវចំពោះបញ្ហានេះ ហើយអង្គបុរេជំនុំជម្រះបានបន្ទោសគាត់ដោយសារតែអន្តរាគមន៍របស់គាត់។ ប៉ុន្តែផ្ទុយមកវិញ ភាពយឺតយ៉ាវអស់រយៈពេលចំនួនប្រាំពីរខែដែលបានដាក់បន្ទុកទៅលើនីតិវិធីទាំងមូលនោះ មិនដែលត្រូវបានគេបញ្ជាក់ហេតុផលទាល់តែសោះ[31]។ សម្រាប់ហេតុផលនេះ គឺជាភាពយឺតយ៉ាវដែលមិនអាចបញ្ជាក់ហេតុផលបាន។

32. ទោះជាសហចៅក្រមស៊ើបអង្កេតផ្តល់តម្លៃ ទៅលើអំណះអំណាងរបស់ក្រុមការពារក្តីបែបណាក៏ដោយ ក៏ខ្លួនមានកាតព្វកិច្ចផ្តន្ទាទោសលើភាពយឺតយ៉ាវនេះ និងការណ៍ដែលនីតិវិធីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នមានកំហុសនោះ[32]។

33. សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចទទួលស្គាល់អំពីស្ថានភាពនេះ៖ ខ្លួនមិនអាចធ្វើមិនដឹងមិនឮចំពោះបរិបទនីតិវិធី ឬ ធ្វើពើជាមិនដឹងមិនឮថា ក្រុមការពារក្តីត្រូវបានគេចំអកឡកឡឺយដោយជាក់ស្តែងនោះទេ។ ហើយក៏មិនអាចធ្វើពើជាមិនដឹងមិនឮថា ឧបាស្រ័យ(ផ្លូវតវ៉ា)ដែលក្រុមការពារក្តីព្យាយាមធ្វើឡើងនោះមិនបានបង្កើតឲ្យមាននូវអានុភាពដែលមានប្រយោជន៍ដែរ។ ដោយពុំទទួលស្គាល់អំពីស្ថានភាពនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើឲ្យសេចក្តីសម្រេចរបស់ខ្លួនបាត់បង់នូវមូលដ្ឋានផ្លូវច្បាប់។

## ២) សេចក្តីសម្រេចបដិសេធដោះលែងឲ្យមានសេរីភាពឈរលើមូលដ្ឋាននៃភាពធ្ងន់ធ្ងរនៃអង្គហេតុដែលបានស៊ើបអង្កេត

---

[31] អង្គបុរេជំនុំជម្រះយល់ឃើញថា សម្រាប់ជាលើកទីមួយ គឺមិនអាចលើកឡើងជាផ្ទាល់មាត់ និងនៅក្នុងពេលសវនាការ នូវអំណះអំណាងដែលមិនបានលើកឡើងជាមុន ដើម្បីគាំទ្រការសរសេររបស់ភាគីនានាទេ។ គឺដោយឈរលើមូលដ្ឋាននេះហើយដែលអង្គបុរេជំនុំជម្រះបានបដិសេធមិនគិតគូរដល់បញ្ហានៃការបកប្រែ ហើយដែលបានយល់ឃើញថា ខ្លួនអាចវិនិច្ឆ័យអំពីនីត្យានុកូលភាពនៃការឃុំខ្លួនបណ្តោះអាសន្នបានដោយគ្រាន់តែសម្អាងលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ។ (សេចក្តីជូនដំណឹងមកក្រុមការពារក្តីទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/27* កថាខណ្ឌ ៦)។ ផ្ទុយមកវិញ អង្គបុរេជំនុំជម្រះមិនដែលលើកឡើងទាល់តែសោះអំពីមូលដ្ឋានត្រឹមត្រូវនៃគោលជំហររបស់ក្រុមការពារក្តី ទាក់ទងនឹងការរំលោភសិទ្ធិរបស់ក្រុមការពារក្តី និងសមត្ថភាពរបស់ក្រុមការពារក្តីក្នុងការការពារកូនក្តីរបស់ខ្លួនប្រកបដោយអត្ថប្រយោជន៍ ដោយគ្មានការបកប្រែឯកសារសំណុំរឿង។ ទាក់ទងនឹងចំណុចនេះ អង្គបុរេជំនុំជម្រះត្រូវស្តាប់ភាគីនានានៅក្នុងសវនាការជាសាធារណៈ នៅថ្ងៃទី៤ ខែធ្នូ។

[32] ទាក់ទងនឹងចំណុចនេះ សូមអាន ការកត់សម្គាល់របស់ក្រុមការពារក្តីទាក់ទងការបន្តការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១៤ វិច្ឆិកា ២០០៨ *ឯកសារតុលាការ C26/3* កថាខណ្ឌ ២២ ដល់ ២៤។

34. ថ្វីបើ "សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលជនត្រូវបានគេចោទ មិនមែនជាឧបសគ្គដាច់ខាតចំពោះការដោះលែងឲ្យមានសេរីភាពវិញក៏ដោយ" ក៏សហចៅក្រម យល់ស្របថា "យ៉ាងហោចណាស់នេះជាកត្តាមួយដែលត្រូវយកមកពិនិត្យពិចារណា នៅក្នុងការ ពិនិត្យលក្ខណៈវិនិច្ឆ័យដើម្បីសម្រេចរក្សាទុកការឃុំខ្លួនបណ្ដោះអាសន្ន និងលក្ខណៈវិនិច្ឆ័យត្រឹម ត្រូវនៃវិធានការណ៍"[33]។

35. ជាការពិត សហចៅក្រមស៊ើបអង្កេតមានករណីយកិច្ចវាយតម្លៃទៅតាមជាក់ស្ដែងនូវហានិភ័យ ដែលបង្កឡើងដោយការដោះលែងជនត្រូវចោទឲ្យមានសេរីភាព។ ជាឧទាហរណ៍ ប្រសិនបើយល់ ឃើញថា ជនត្រូវចោទអំពីឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរម្នាក់អាចមានហេតុផលច្រើនទៀតដើម្បីគេចផុតពី យុត្តិធម៌ ឬ ពីទោសជាប់ពន្ធនាគារដ៏ធ្ងន់ធ្ងរជាយថាហេតុណាមួយ គឺត្រូវបង្ហាញថាជននេះពិតជា អាចគេចផុតបានមែន ហើយឥរិយាបថពីអតីតកាលរបស់ជននេះបង្ហាញថាមានបំណងបែបនេះ មែន[34]។

36. ដូច្នេះ នៅពេលដែលចៅក្រមចោទសួរខ្លួនឯង អំពីមូលដ្ឋានត្រឹមត្រូវនៃការដោះលែងឲ្យមាន សេរីភាពវិញ និងនៅពេលដែលជនត្រូវចោទត្រូវបានគេសន្មតជាមុនថាគ្មានទោសពិតមែននោះ គឺ មានតែការពិនិត្យឲ្យបានជាក់ច្បាស់នូវហានិភ័យ "ដ៏ជាក់ស្ដែង" ដែលបង្កឡើងដោយការដោះលែង ប៉ុណ្ណោះ ដែលឆ្លើយតបទៅនឹងតម្រូវការដែលបានកំណត់តាមច្បាប់។ ភាពធ្ងន់ធ្ងរនៃអង្គហេតុដែល កំពុងស៊ើបអង្កេតមិនត្រូវបង្កើតបានជាលក្ខណៈវិនិច្ឆ័យតែមួយដោយឯកឯងនោះទេ។ ដូច្នេះ យើង នឹងមិនពិបាកយល់ទេថា ការទាមទារនេះគឺរឹតតែមានសារៈសំខាន់ខ្លាំងថែមទៀត នៅពេលដែល ភាពស្របច្បាប់នៃការចោទប្រកាន់និងនៃការស៊ើបអង្កេតត្រូវបានចោទឡើង នៅក្នុងពេលស្នើឲ្យ មានការដោះលែងឲ្យមានសេរីភាព។

37. នៅក្នុងរឿងក្ដីនេះ គឺចេញពីដីកាសម្រេចបដិសេធដោះលែងឲ្យមានសេរីភាពដែលសហចៅក្រម ស៊ើបអង្កេតសម្អាងលើភាពធ្ងន់ធ្ងរនៃអង្គហេតុដែលបានស៊ើបអង្កេត ដើម្បីប្រឆាំងនឹងការដោះលែង

---

[33] ដីកាសម្រេចបដិសេធការដោះលែងឲ្យមានសេរីភាព កថាខណ្ឌ ១៩។

[34] បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ថ្ងៃទី១៥ មករា ២០០៨ *ឯកសារ C22/1/5* កថាខណ្ឌ ៣៣។

ឲ្យមានសេរីភាពនេះ[35] និង(បដិសេធមិន) ផ្ដល់លទ្ធភាពឲ្យដំណោះស្រាយណាមួយជំនួសឲ្យការរក្សាទុកការឃុំខ្លួន[36]។

38. ការទាញរកហេតុផលនេះ ជួនកាលអាចឲ្យគេយល់បាន ជួនកាលត្រូវពន្យល់ឲ្យបានច្បាស់លាស់។ ប៉ុន្តែ ជានិច្ចកាលវាជាមូលហេតុទីមួយនៃការទាញរកហេតុផលរបស់សហចៅក្រមស៊ើបអង្កេត។ ជាឧទាហរណ៍ យើងមានសិទ្ធិចោទសួរខ្លួនយើងអំពីអ្វីដែលសហចៅក្រមស៊ើបអង្កេតចង់បកស្រាយនៅពេលដែលខ្លួនអះអាងថា "ភាពធ្ងន់ធ្ងរនៃអង្គហេតុដែលបានចោទប្រកាន់ចំពោះជនត្រូវចោទ (...) អាចបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់សាម៉ីជន"[37] ឬនៅពេលដែលខ្លួនធ្វើឲ្យគេយល់ដោយមិនបាច់សម្ដែងឲ្យចំថា ភាពធ្ងន់ធ្ងរនៃអង្គហេតុដែលបានស៊ើបអង្កេតបង្កើតបានជាឧបសគ្គមួយ "ទាក់ទងនឹង" ការដោះលែងឲ្យមានសេរីភាពវិញ[38]។

39. ចំណែកឯការពិនិត្យលទ្ធភាពនៃដំណោះស្រាយជំនួសឲ្យការរក្សាទុកការឃុំខ្លួនវិញ សហចៅក្រមស៊ើបអង្កេតអះអាងថា "ភាពធ្ងន់ធ្ងរនៃអង្គហេតុដែលលោក ខៀវ សំផន ត្រូវបានដាក់ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ធ្វើឲ្យហានិភ័យដែលវិធាន ៦៣(៣)(ខ) ព្យាយាមបង្ការកាន់តែមានសភាពធ្ងន់ធ្ងរឡើង" ហើយថា "ពុំមានវិធានការណ៍ត្រួតពិនិត្យតាមផ្លូវតុលាការណាមួយផ្សេងទៀតអាចធានាប្រសិទ្ធិភាពនៃបទបញ្ញត្តិខាងលើនេះបានទេ។"[39]។

40. បើនិយាយតាមបែបផ្សេង បន្ទាប់ពីបានសម្រេចថា លក្ខខណ្ឌដែលអាចបញ្ជាក់អំពីភាពត្រឹមត្រូវនៃការឃុំខ្លួនត្រូវបានបំពេញហើយនោះ សហចៅក្រមស៊ើបអង្កេតសម្អាងលើភាពធ្ងន់ធ្ងរនៃអង្គហេតុតែប៉ុណ្ណោះ ដើម្បីបដិសេធការដោះលែងឲ្យមានសេរីភាព ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។ នេះគឺគ្រាន់តែដើម្បីបដិសេធវិធានការណ៍ត្រួតពិនិត្យតាមផ្លូវតុលាការនៃនីតិវិធីសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិប៉ុណ្ណោះ ដោយមិនអើពើចំពោះវិធាន ៦៥ នៃវិធានផ្ទៃក្នុងឡើយ។។

41. ការពិនិត្យនេះគឺពិតជាឆាប់រហ័សពេកហើយ។ គឺមិនមែនដោយសារតែការដោះលែងឲ្យមានសេរីភាពវិញ - ដោយចាត់ទុកថាបញ្ហានេះត្រូវបានបង្ហាញឲ្យឃើញ - អាចបង្កឲ្យមានហានិភ័យកាន់តែច្រើនដោយសារតែភាពធ្ងន់ធ្ងរនៃអង្គហេតុដែលបានលើកឡើងនោះទេ ដែលត្រូវគិតថា

---

[35] ដីកាសម្រេចបដិសេធការដោះលែងឲ្យមានសេរីភាព កថាខណ្ឌ ១៩ និង ២១។

[36] ដីកាសម្រេចបដិសេធការដោះលែងឲ្យមានសេរីភាព កថាខណ្ឌ ២៥។

[37] ដីកាសម្រេចបដិសេធការដោះលែងឲ្យមានសេរីភាពវិញ កថាខណ្ឌ ២១។

[38] ដីកាសម្រេចបដិសេធការដោះលែងឲ្យមានសេរីភាពវិញ កថាខណ្ឌ ១៩។

[39] ដីកាសម្រេចបដិសេធការដោះលែងឲ្យមានសេរីភាពវិញ កថាខណ្ឌ ២៥។

ហានិភ័យទាំងនេះមិនអាចបង្ការការពារបានដោយវិធានការណ៍នៃការត្រួតពិនិត្យតាមផ្លូវតុលាការ។ នេះគឺមិនមែនដោយសារតែការរក្សាទុកការឃុំខ្លួនបណ្តោះអាសន្ន អាចបង្កើតបានជាវិធានការណ៍បង្ការការពារដ៏មានប្រសិទ្ធភាពមួយទេ ដែលវិធានការណ៍នេះចាំបាច់ជាវិធានការណ៍ដែលអាចធ្វើបានតែមួយគត់នោះ!

42. នៅចំពោះមុខហានិភ័យនៃការឃុំខ្លួនដែលធ្វើឡើងតាមតែអំពើចិត្តដែលបានពន្យារពេល អង្គបុរេជំនុំជម្រះត្រូវបញ្ជាក់ដោយយកចិត្តទុកដាក់ថា ជនត្រូវចោទមិនត្រូវបានរក្សាទុកក្នុងការឃុំខ្លួនដោយឥតប្រយោជន៍នោះទេ ជាពិសេសទាក់ទងនឹងលទ្ធភាពឱ្យមានដំណោះស្រាយជំនួសណាមួយ។ ដូច្នេះ ត្រូវមានការសិក្សាឱ្យបានច្បាស់លាស់ជាក់ស្តែងលើដំណោះស្រាយទាំងនេះ និងដោយមិនអាស្រ័យនឹងភាពធ្ងន់ធ្ងរនៃអង្គហេតុដែលបានស៊ើបអង្កេតឡើយ។

## ខ. សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតគឺប្រឡាក់ប្រឡូសដោយកំហុសផ្នែកអង្គហេតុ

43. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត "រំឭកថា ការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើទៅបាន ប្រសិនបើលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងប្រាំដែលចែងក្នុងមាត្រា ៦៣(៣) ត្រូវបានបំពេញ ដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនចាំបាច់ត្រូវពិនិត្យលើលក្ខណៈវិនិច្ឆ័យនីមួយៗនោះទេ"[40]។

44. ប៉ុន្តែ ក្រុមការពារក្តីសូមបញ្ជាក់ថា អត្ថិភាពនៃហេតុផលទំនងជាពិតដែលគិតថា ជននោះបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលគេបានចោទប្រកាន់ចំពោះខ្លួន គឺជាលក្ខខណ្ឌតែមួយគត់ដ៏ចាំបាច់មិនអាចខ្វះបានចំពោះនិយតភាពនៃការរក្សាទុកការឃុំខ្លួន[41]។ ប៉ុន្តែ នៅត្រង់ចំណុចនេះ សហមេធាវីការពារក្តីមិនអាចការពារខ្លួនឱបានពេញលេញនោះទេ[42]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតលែងអាចសម្អាងការបដិសេធការដោះលែងឱ្យមានសេរីភាពរបស់ខ្លួន លើលក្ខណៈវិនិច្ឆ័យនេះបានទៀតហើយ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីរយៈពេលមួយដែលបានស្ថិតនៅក្នុងការឃុំខ្លួន លក្ខណៈវិនិច្ឆ័យនេះលែងជាលក្ខណៈកំណត់ហើយ[43]។ ដូច្នេះ ក្រុមការពារក្តីសូមស្នើទៅអង្គបុរេ

---

[40] ដីកាសម្រេចបដិសេធការដោះលែងឱ្យមានសេរីភាព កថាខណ្ឌ ១៤។

[41] សំណើបន្ទាន់សុំឱ្យមានការដោះលែងឱ្យមានសេរីភាពវិញ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C40* កថាខណ្ឌ ២៧

[42] នៅត្រង់ចំណុចនេះ សូមអាន ការកត់សម្គាល់របស់ក្រុមការពារក្តីចំពោះការបន្តការឃុំខ្លួន ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/3*។

[43] សំណើបន្ទាន់សុំឱ្យមានការដោះលែងឱ្យមានសេរីភាព ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C40* កថាខណ្ឌ២៨

ជំនុំជម្រះ ឲ្យគ្រាន់តែធ្វើមិនដឹងមិនឮចំពោះសេចក្តីកត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងចំណុចនេះ តែប៉ុណ្ណោះ។

45. ដោយមិនគិតដល់បរិបទដែលសំណើសុំត្រូវបានធ្វើឡើង ក្រុមការពារក្តីយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនមានលក្ខខណ្ឌណាមួយ ដែលបញ្ជាក់អំពីភាពត្រឹមត្រូវនៃការឃុំខ្លួនលោក ខៀវ សំផន ទេ ហើយដូចដែលខ្លួនបានលើកឡើងពីកថាខណ្ឌ ៣០ ដល់ ៣៩ នៃសារណានេះ ក្រុមការពារក្តីយល់ឃើញថា តាមពិតទៅ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតគឺគ្រាន់តែសម្អាងលើភាពធ្ងន់ធ្ងរនៃអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបអង្កេតតែប៉ុណ្ណោះ។

### ១) សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញឲ្យឃើញថា មានហានិភ័យនៃការដាក់សម្ពាធទៅលើសាក្សីឬជនរងគ្រោះទេ

46. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា "មានហានិភ័យនៃការដាក់សម្ពាធពិតប្រាកដ" ហើយហានិភ័យនេះ "ត្រូវបានបញ្ជាក់ដោយការថ្លែងជាសាធារណៈនានារបស់ជនត្រូវចោទ"[44]។

47. ដើម្បីបញ្ជាក់ពីលក្ខណៈពិតប្រាកដនៃហានិភ័យនេះ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ១) "រយៈពេលឃុំខ្លួនកន្លងមកមិនបានធ្វើឲ្យហានិភ័យនេះរលប់បាត់នោះទេ ប៉ុន្តែផ្ទុយទៅវិញហានិភ័យនេះកាន់តែកើនឡើងថែមទៀត។" ២) លោក ខៀវ សំផន អាចមើលសំណុំរឿងស៊ើបអង្កេត ហើយនៅក្នុងសំណុំរឿងនេះមាន "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ៣) មាន "ហានិភ័យពិតប្រាកដមួយដែលថាសាក្សីអាចនឹងបដិសេធមិនចូលរួមក្នុងនីតិវិធីតទៅទៀត" ៤) មានហេតុផលដែលធ្វើឲ្យគិតថាសាក្សីទាំងនេះអាចនឹងទទួលរងនូវការដាក់សម្ពាធ "ដោយសារថាពួកគេគឺធ្លាប់ជាមនុស្សក្រោមបង្គាប់របស់ជនត្រូវចោទ ឬដោយលក្ខណៈទូទៅ ជនត្រូវចោទជាមនុស្សមានឥទ្ធិពលទៅលើពួកគេ"។

48. ពិតមែនតែមានហេតុផលដ៏ច្រើន ក៏មិនមានចំនុចណាមួយក្នុងចំណោមចំនុចទាំងបួននេះដែលត្រូវបានយកមកវិភាគម្តងមួយៗ បង្ហាញឲ្យឃើញថាមានហានិភ័យពិតប្រាកដក្នុងពេលបច្ចុប្បន្នឡើយ ។ ដូច្នេះ បើយើងមើលទៅលើការលើកហេតុផលរបស់សហចៅក្រមស៊ើបអង្កេត ហានិភ័យនៃការដាក់សម្ពាធទៅលើសាក្សីគឺជាការពិតចាប់តាំងពីពេលដែលការស៊ើបអង្កេតបានបើកធ្វើតាំងពីច្រើនខែកន្លងមកម្លេះ។ ម្យ៉ាងទៀត ការដែលជនត្រូវចោទអាចមើលសំណុំរឿងស៊ើបអង្កេត ហើយនៅក្នុងសំណុំរឿងនេះមានពត៌មានដាក់បន្ទុកដែលបានផ្តល់ឲ្យដោយសាក្សី ដែលតាមការយល់ឃើញ

[44] ដីកាបដិសេធការដោះលែងឲ្យមានសេរីភាព កថាខណ្ឌ ១៦។

របស់សហចៅក្រមស៊ើបអង្កេត គឺពួកគេសុទ្ធតែជាមនុស្សក្រោមបង្គាប់របស់ជនត្រូវចោទ ឬក៏ជាមនុស្សដែលស្ថិតក្រោមឥទ្ធិពលរបស់ជនត្រូវចោទ។

49. ជាបឋម ការលើកហេតុផលនេះគឺផ្អែកលើការមិនសមហេតុផលទីមួយដែលនិយាយថា ការដែលដាក់ឲ្យនៅក្រៅឃុំមិនត្រូវបានបង្ហាញថាមានហេតុផលសមស្របបានទេ ដោយសារតែការស៊ើបអង្កេតកំពុងតែដំណើរការនៅឡើយ។ តើការស៊ើបអង្កេតនេះមិនមែនជាក្របខ័ណ្ឌតែមួយគត់ដែលជាកត្តាបណ្តាលឲ្យមានការឃុំជនត្រូវចោទ និងបណ្តាលឲ្យមានសំណើសុំនៅក្រៅឃុំទេឬយ៉ាងណា?

50. បន្ទាប់មកទៀត ការលើកហេតុផលនេះត្រូវបានគាំទ្រដោយការប៉ះពាល់ដល់សិទ្ធិជាសារវន្តរបស់ជនត្រូវចោទ ដែលជាសិទ្ធក្នុងការមើលឯកសារនៃសំណុំរឿងព្រហ្មទណ្ឌ[45]។ ចំពោះបញ្ហានេះ ក្រុមមេធាវីការពារក្តីសូមរំឭកថា សហចៅក្រមស៊ើបអង្កេតជាអ្នកទទួលបន្ទុកការពារសាក្សីក្នុងការគោរពសិទ្ធិរបស់ជនត្រូវចោទ ហើយសហចៅក្រមស៊ើបអង្កេតត្រូវរក្សានូវសមតារវាងផលប្រយោជន៍នៅចំពោះមុខ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតជាអ្នកចេញវិធានការការពារដែលអាចធានានូវសន្តិសុខរបស់ពួកគេជាចាំបាច់នៅក្នុងគ្រប់ករណី[46]។ វិធីដែលត្រូវដាក់ទម្ងន់ទៅលើជនត្រូវចោទ នូវផលវិបាកជាអវិជ្ជមានក្នុនការអនុវត្តសិទ្ធរបស់ខ្លួន គឺផ្ទុយទៅនឹងស្មារតីរបស់ច្បាប់និងច្បាប់អន្តរជាតិ។

51. តាមការពិត ការលើកហេតុផលរបស់សហចៅក្រមស៊ើបអង្កេតភ្ជាប់ជាសំខាន់ទៅលើអំណាចនិងឋានានុក្រមរបស់លោក ខៀវ សំផន ដែលសន្មត់ថាខ្ពស់ជាងសាក្សីនៅក្នុងរឿងនេះ។ ការលើកហេតុផលនេះមិនត្រឹមតែផ្ទុយទៅនឹងសច្ចធារណ៍និរទោសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនគោរពតាមកំរិតបទដ្ឋានរបស់អង្គបុរេជំនុំជំរះ ក្នុងការវិភាគពីហានិភ័យពិតប្រាកដនៃការដាក់សម្ពាធទៀតផង។

52. ជាការពិតណាស់ នៅក្នុងសំណុំរឿងរបស់លោក អៀង សារី អង្គបុរេជំនុំជម្រះបានចាត់ទុកថាមិនមានការបង្ហាញឲ្យឃើញពីហានិភ័យនៃការដាក់សម្ពាធទេ ពិតមែនតែ "ជនត្រូវចោទមានឥទ្ធិពលចាំបាច់ ដើម្បីជំរុញអ្នកដ៏ទៃឲ្យដាក់សម្ពាធទៅលើសាក្សីនិងជនរងគ្រោះក៏ដោយ"។ ផ្ទុយទៅវិញ គឺត្រូវតែបង្ហាញពី "ភស្តុតាងទាក់ទិននឹងសកម្មភាពឬអកប្បកិរិយាពីមុនដែលបង្ហាញថា មាន

---

[45] មាត្រា ៣៥ (ក) នៃច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក។

[46] មាត្រា២៣ នៃកិច្ចព្រមព្រៀង៖ "ចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវពិនិត្យលើការការពារជនរងគ្រោះនិងសាក្សី។ វិធានការការពាររួមមានដូចជា ការរៀបចំសវនាការជាសម្ងាត់ ហើយការការពារអត្តសញ្ញាណរបស់ជនរងគ្រោះឬសាក្សី" សូមមើលផងដែរនូវមាត្រា ៣៣ នៃច្បាប់ស្តីពីការបង្កើតឲ្យមាន អ.វ.ត.ក។

ហានិភ័យជាក់ស្តែងដែលប្រើប្រាស់ឥទ្ធិពលនេះដើម្បីគំរាមសាក្សីឬជនរងគ្រោះ"[47]។ ដោយឡែក អង្គបុរេជំនុំជម្រះបានសរុបថា ពុំមានបង្ហាញពីហានិភ័យដែលលោកអៀង សារី កៀបសង្កត់លើសាក្សីទេ។

53. ដើម្បីប្រើជាភស្តុតាងសំរាប់បញ្ជាក់ចំពោះករណីលោក ខៀវ សំផន - សហចៅក្រមស៊ើបអង្កេតបានលើកឡើងតែឯកសារមួយគត់ ៖ នោះគឺសេចក្តីថ្លែងរបស់លោក ខៀវ សំផន ដែលបានធ្វើឡើងកាលពី ៦ ឆ្នាំមុន ទៅកាន់ភ្នាក់ងារសារពត៏មានបារាំង AFP និងដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត[48]។

54. នៅក្នុងសេចក្តីថ្លែងនេះ លោក ខៀវ សំផន សំដែងនូវសេចក្តីព្រួយបារម្ភចំពោះសុវត្ថិភាពរបស់សាក្សី និងជនរងគ្រោះ ក្នុងករណីដែលបង្កើតឲ្យមានតុលាការសំរាប់កាត់ទោសមេដឹកនាំខ្មែរក្រហម។ សហចៅក្រមស៊ើបអង្កេតបកស្រាយសេចក្តីថ្លែងនេះថាជា "សេចក្តីថ្លែងជាសាធារណៈរបស់ជនត្រូវចោទដែលលើកឡើងពីការគម្រាមកំហែងសងសឹក" (ជាការកត់សំគាល់របស់ពួកយើង)។

55. ការណ៍ដែលលោក ខៀវ សំផន អាចធ្វើការកត់សំគាល់ ក្នុងឆ្នាំ២០០២ ពីការកើតមានការគម្រាមកំហែងចំពោះសន្តិសុខបុគ្គលនោះ មិនអាចបង្កើតបានជាភស្តុតាងដែលបញ្ជាក់ថា គាត់បានប្រើ "ឥទ្ធិពលរបស់គាត់ដើម្បីគំរាមកំហែងសាក្សីឬជនរងគ្រោះទេ"។ សេចក្តីសន្និដ្ឋានដែលទាញចេញអំពីការសន្មត់លើការប្រើឥទ្ធិពលនិងអំពីមតិតែមួយរបស់សារពត៌មាន គឺមិនសមហេតុផលទេ។

56. ជាទីបញ្ចប់នេះ ក្រុមមេធាវីការពារក្តីសូមរំឭកថា ចាប់ពីពេលដែលគាត់ត្រូវបានចាប់ខ្លួនមក លោក ខៀវ សំផន បានសហការយ៉ាងពេញលេញជាមួយអាជ្ញាធរតុលាការ[49] ហើយថា គាត់នៅតែបន្តសហការតទៅទៀត។ ភាពសុច្ចរិតបំផុត បុគ្គលិកលក្ខណៈ និងប្រវត្តិរបស់លោក ខៀវ សំផន គឺកាន់តែបង្ហាញថា ត្រូវតែមានការបកស្រាយសេចក្តីថ្លែងនេះផ្សេងពីនេះ។

---

[47] សេចក្តីបកប្រែក្រៅផ្លូវការ, សេចក្តីសម្រេចទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង សារី កថាខណ្ឌ ៩៨ និង ៩៩ *ឯកសារតុលាការ C22/I/74, ERN 00232976*។

[48] ភ្នាក់ងារសារពត៌មានបារាំង "មេដឹកនាំខ្មែរក្រហម ចង់បាន គណៈកម្មការស្វែងរកការពិតមួយ ជាជាង ការកាត់ក្តី" (សេចក្តីបកប្រែក្រៅផ្លូវការ) ថ្ងៃទី១ ខែធ្នូ ២០០២ ឯកសារតុលាការ D29, ERN 00149391។

[49] សូមមើលជាអាទិ៍COMPAIN(F) "ខ្មែរក្រហម៥នាក់ឲ្យជាប់ពិរុទ្ធ កន្លងរយៈពេល៣០ឆ្នាំក្រោយ" សារពត៌មាន Le Figaro ថ្ងៃ១៤ ខែតុលា ឆ្នាំ២០០៧។

57. ទាក់ទងទៅនឹងហានិភ័យ "ពិតប្រាកដ" ក្នុងការមិនរក្សាទុកភស្តុតាង សហចៅក្រមស៊ើបអង្កេតផ្អែកទៅលើ "ហានិភ័យពិតប្រាកដដែលសាក្សីបដិសេធន៍មិនចូលរួមនីតិវិធីតទៅទៀត" (ជាការកត់សំគាល់របស់យើង) ក្នុងករណីដែលលោក ខៀវ សំផន ត្រូវបានដោះលែង។

58. ដូច្នេះ ជាថ្មីម្តងទៀត សហចៅក្រមស៊ើបអង្កេតមិនផ្អែកទៅលើអង្គហេតុដែលបានបង្ហាញឲ្យឃើញតាមរយៈភស្តុតាងឡើយ[50] ប៉ុន្តែបែរជាផ្អែកទៅលើការសន្មតថា ហានិភ័យ មួយអាចកើតមានឡើងទៅវិញ។ ដូច្នេះ សំរាប់សហចៅក្រមស៊ើបអង្កេត ភាពប្រាកដប្រជានៃហានិភ័យដែលធ្វើឲ្យបាត់បង់ភស្តុតាងត្រូវបានបង្ហាញឲ្យឃើញចាប់ពីពេលដែលកើតមាន ហានិភ័យមួយទៀត។ ផ្ទុយទៅវិញ លក្ខណៈពិតប្រាកដនៃ ហានិភ័យគឺទាញចេញអំពីតួនាទីរបស់សាក្សីដែលបានសន្មតនៅក្នុងអង្គហេតុដែលដាក់បន្ទុក! អង្គបុរេជំនុំជំរះមិនអាចនឹងទទួលយកការលើកហេតុផលបែបនេះទេ។

59. ជាការសន្និដ្ឋាន សហមេធាវីការពារក្តីយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញឲ្យឃើញពីហានិភ័យពិតប្រាកដណាមួយទេ។ ផ្ទុយទៅវិញ សហមេធាវីការពារក្តីយល់ឃើញថា ហានិភ័យនេះដែលមិនត្រូវបានបង្ហាញឲ្យឃើញនោះ គឺមិនមានទាល់តែសោះ ហើយនៅត្រង់ចំនុចនេះ សំដៅទៅលើការបកស្រាយនានាសម្រាប់ជាការគាំទ្រសំណើសុំនៅក្រៅឃុំ។

### ២) សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញឲ្យឃើញថា ការដោះលែងលោក ខៀវ សំផន នឹងធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈទេ

60. ដោយលើកយកការបកស្រាយរបស់អង្គបុរេជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា លក្ខខណ្ឌនៃការការពារថែរក្សាសណ្តាប់ធ្នាប់សាធារណៈត្រូវបានគោរព ១) "<u>បើសិនជាមានអង្គហេតុនានាដែលអាចបង្ហាញបាន</u>" ២) <u>ការដាក់ឲ្យនៅក្រៅឃុំនឹងអាចបណ្តាលឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដោយពិតប្រាកដ</u> (...) ដែលប្រការនេះទងទៅនឹងផ្នែកមួយនៃការគ្រោងទុកជាមុនច្បាស់ណាស់" និង ៣) ប្រសិនបើសណ្តាប់ធ្នាប់សាធារណៈ<u>នៅតែ</u>ត្រូវបានគម្រាមកំហែងពិតប្រាកដមែន"[51]។

61. ក្រុមមេធាវីការពារក្តីបកស្រាយដូចគ្នានឹងការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេត និង អង្គបុរេជំនុំជម្រះដែរ ហើយយល់ឃើញថា វាគឺជាការសាកល្បងដ៏សមស្របមួយក្នុងការវាយតំលៃភាពប្រាកដប្រជានៃហានិភ័យ។ នៅត្រង់ចំណុចនេះ ក្រុមមេធាវីការពារក្តីលើកឡើងនូវយុត្តិសាស្ត្រសម

---

[50] ទោះជាណាក៏ដោយ ចៅក្រមត្រូវតែស្រង់យកសេចក្តីថ្លែងដោយប្រយ័ត្នប្រយែងខ្ពស់បំផុត។

[51] ដីការបដិសេធន៍ដោះលែងឲ្យនៅក្រៅឃុំ កថាខណ្ឌទី១៧។

ហេតុសមផលមួយស្តីពីបញ្ហានេះ ដែលចេញដោយតុលាការសិទ្ធិមនុស្សរបស់សហគមន៍អឺរ៉ុប[52]។ ប៉ុន្តែ ក្រុមមេធាវីការពារក្តីយល់ឃើញថា ហានិភ័យនេះមិនត្រូវបានបង្ហាញឲ្យឃើញទេ នៅក្នុងរឿងក្តីនេះ។

62. ដូច្នេះ លក្ខខណ្ឌបីត្រូវតែលើកយកមកនិយាយហើយមិនអាចខ្វះមួយណាបានឡើយ៖ ១) ការតម្រូវឲ្យមានភស្តុតាង៖ អង្គហេតុដែលលើកឡើងត្រូវតែអាចបង្ហាញថា ការដោះលែងឲ្យនៅក្រៅឃុំ អាចនឹងបណ្តាលឲ្យមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ២) ការតម្រូវឲ្យមានការប៉ះពាល់៖ ការដោះលែងឲ្យនៅក្រៅឃុំពិតជាបណ្តាលឲ្យមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈប្រាកដមែន ទោះបីជាសំរាប់បច្ចុប្បន្នកាលឬអនាគតកាលក្តី ៣) ការតម្រូវឲ្យមានលក្ខណៈជាអចិន្ត្រៃយ៍៖ ការប្រឈមមុខថានឹងមានការប៉ះពាល់នេះ ត្រូវតែមានក្នុងពេលបច្ចុប្បន្ន ។

63. ក្នុងរឿងក្តីនេះ មិនមានអ្វីជាសំអាងផ្ទុយមកវិញទេថា "ផលប៉ះពាល់នៃរបបខ្មែរក្រហមទៅលើសង្គមកម្ពុជាមិនបានរលប់បាត់អស់នៅឡើយទេ ហើយថា ផ្នែកមួយនៃសង្គមទទួលរងភាពមិនប្រក្រតីបណ្តាលមកពីស្នាមរបួសផ្លូវចិត្ត" ឬក៏ថា "ចំណាប់អារម្មណ៍របស់ប្រជាពលរដ្ឋនិងសារពត៌មានកម្ពុជាទៅលើអង្គជំនុំជម្រះវិសាមញ្ញ និងទៅលើនីតិវិធីតុលាការដែលកំពុងតែដំណើរការនេះបង្ហាញថា ជានិច្ចកាល វាគឺជាប្រធានបទមួយដែលទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំង"[53]។

64. ក៏ប៉ុន្តែ វាជាការហួសហេតុមួយដែលសន្និដ្ឋានអំពីបញ្ហានេះ ដោយផ្អែកទៅលើអង្គហេតុ និងលើបរិបទមួយដែលល្បីថាមានលក្ខណៈផុយស្រួយថា "សេចក្តីសម្រេចដោះលែងឲ្យនៅក្រៅឃុំ (...) អាចនឹងបណ្តាលឲ្យកើតមានភាពក្តៅក្រហាយដែលអាចបង្កឲ្យមានអំពើហឹង្សាកើតមានឡើង"[54]។

65. ជាដំបូង សហចៅក្រមស៊ើបអង្កេតយោងទៅលើអង្គហេតុ - ដែលថាភាពមានរបួសស្នាមផ្លូវចិត្តរបស់សង្គមកម្ពុជា និងចំណាប់អារម្មណ៍របស់ប្រជាពលរដ្ឋនិងសារពត៌មានកម្ពុជាទៅលើនីតិវិធីតុលាការដែលកំពុងតែតំនើរការ - មិនអាចបង្ហាញបានថា ការដោះលែងឲ្យនៅក្រៅឃុំ អាចនឹងបណ្តាលឲ្យមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ[55]។

---

[52] ដីកាសម្រេចបដិសេធដោះលែងឲ្យនៅក្រៅឃុំ កថាខណ្ឌទី៤៦។

[53] ដីកាសម្រេចបដិសេធដោះលែងឲ្យនៅក្រៅឃុំ កថាខណ្ឌទី១៨។

[54] ដីកាសម្រេចបដិសេធដោះលែងឲ្យនៅក្រៅឃុំ កថាខណ្ឌទី១៩។

[55] ករណីនេះ ក្នុងសាលដីការបស់តុលាការ ខូអាយ ដែលនៅក្នុង នោះបានលើកយកមកវែកញែកពីភាពច្របូកច្របល់គ្នារវាងទម្ងន់នៃអង្គហេតុនិងការបង្ករការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សាលដីកានេះអាចឲ្យយើងយល់ពីភាពខុសគ្នានៃសញ្ញាណទាំងពីរនេះ។ នៅក្នុងសំណុំរឿងនេះ វាច្បាស់ណាស់ថា ជនរងគ្រោះទទួលរងព្យសនៈកម្ម ធ្ងន់ធ្ងរ ក៏ប៉ុន្តែអ្វីដែលត្រូវតែរកភស្តុតាងមកបញ្ជាក់មិនមែនការបន្តមាននូវ ការប៉ះពាល់ដល់ជនរងគ្រោះទេ គឺការបន្តមាននូវការប៉ះពាល់ដល់សណ្តាប់ធ្នាប់

66. ឧទាហរណ៍ ក្នុងសាលក្រមរបស់តុលាការឧក្រិដ្ឋតំបន់ Gironde លើសំណុំរឿងក្តីរបស់ Papon[56] ដែលក្នុងសាលក្រមនោះចៅក្រមបានសម្រេចថា ៖ "យល់ឃើញថា (...) ប្រសិនបើយើងសន្មត់ថា គ្មានជនណាមួយអាចថាមិនដឹងពីអារម្មណ៍ និងមនោសញ្ចេតនារបស់ភាគីជនរងគ្រោះ ជាដើម បណ្តឹងរដ្ឋប្បវេណីក្តី ឬពុំមែនក្តី ដែលអារម្មណ៍ និងមនោសញ្ចេតនានោះ កើតចេញមកពីស្ថានភាព ដែលជាប់ពាក់ព័ន្ធជាមួយការបង្កើតអោយមានការជំនុំជម្រះបទឧក្រិដ្ឋមួយ ព្រមទាំងទស្សនៈវិស័យ នៃការរំលឹកឡើងវិញដ៏សែនលំបាកនូវការឈឺចាប់ដែលបានកើតមានឡើងនោះ យើងមិនអាច សន្និដ្ឋានបានថា ស្ថានភាពនេះពិតជាបានបង្កអោយមានការប៉ះទង្គិចដល់សណ្តាប់ធ្នាប់សាធារណៈ ដែលជាមូលហេតុនាំអោយមានការឃុំខ្លួនបណ្តោះអាសន្ន ហើយដែលការឃុំខ្លួននេះមិនត្រូវបាន ទាមទារក្នុងដំណាក់កាលណាមួយនៃនីតិវិធីឡើយ"។

67. ជាក់ស្តែង ការឃុំខ្លួនបណ្តោះអាសន្នត្រូវបានទាមទារដោយ សហព្រះរាជអាជ្ញាចាប់តាំងពីដំណាក់ កាលដំបូងនៃដំណើរការនីតិវិធីមកម្ល៉េះ។ ក៏ប៉ុន្តែ សម្រាប់ក្រុមមេធាវីការពារក្តីមិនបានយល់ឃើញ ថាវិធានការនេះត្រូវបានទាមទារក្នុងគោលដៅដើម្បីបញ្ឈប់ ឬទប់ស្កាត់ការរំលោភបំពានណាមួយ លើសណ្តាប់ធ្នាប់សាធារណៈឡើយ។ ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តីយល់ឃើញថា វិធានការ នេះត្រូវបានប្រើប្រាស់ ដើម្បីសម្របទៅនឹងបរិបទជាអន្តរជាតិ និងប្រព័ន្ធផ្សាយពត៌មានសម្រាប់ ការកាត់ទោសមេដឹកនាំខ្មែរក្រហមទៅវិញទេ[57]។

---

សាធារណៈ ឯណោះទេ។ តុលាការក្នុងវយុត្តិសាស្ត្របានធ្វើការសន្និដ្ឋានក្នុងន័យនេះថា "មិនអាចអះអាងបានទេថាអង្គហេតុ ទាំងនេះបណ្តាលឱ្យមាន "ការប៉ះពាល់ពិសេសនិងអចិន្ត្រៃយ៍ណាមួយ" ដល់សណ្តាប់ធ្នាប់សាធារណៈទេ។ ការឈឺចាប់បច្ចុប្បន្ន កាលរបស់ជនរងគ្រោះមិនអាចឱ្យសន្មតបានថា ការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដែលត្រូវបញ្ជាក់ដោយអង្គហេតុ នៅ ឆ្នាំ១៩៨៧ (ដែលចាត់ទុកថា ជាការប៉ះពាល់"ពិសេស") នៅក្នុងរឿងនេះ រហូតថាទាល់តែមានការឃុំខ្លួនបណ្តោះអាសន្នរបស់ ជនX" ទើបអាចបញ្ចប់បញ្ហានេះបានទេ។ អាការៈមិនប្រក្រតីបច្ចុប្បន្នរបស់រងគ្រោះគឺមិនដូចទៅនឹងការប៉ះពាល់"ដែលបន្តមាន" ទៅលើសណ្តាប់ធ្នាប់សាធារណៈទេ។ CHAMBON (P.), GUERY (C.), *Droit et pratique de l'instruction préparatoire*, Dalloz Action 2007/2008, កថាខណ្ឌ 142.43.

[56] នាថ្ងៃប្រកាសសាលក្រមនោះ លោក Papon ត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ/តុលាការ ឧក្រិដ្ឋតំបន់ Gironde, ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩៧, សំណុំរឿងក្តីលោក Papon លើកឡើងក្នុង CHAMBON (P.), GUERY (C.), *Droit et pratique de l'instruction préparatoire*, Dalloz Action 2007/2008, កថាខណ្ឌ 142.43.

[57] ទាក់ទងដល់ចំណុចនេះ ច្បាប់របស់បារាំងចុះថ្ងៃទី៥ ខែមិនា ឆ្នាំ២០០៧ បានចែងថា " (ការប៉ះទង្គិចដល់សណ្តាប់ ធ្នាប់ សាធារណៈ) មិនអាចកើតចេញពីការលេចឮរខ្ទារខ្ទារនូវពត៌មានដែលទាក់ទងដល់រឿងក្តីឡើយ។

68. ក្រុមមេធាវីការពារក្តីយល់ឃើញថា បរិបទដ៏ផុយស្រួយរបស់សង្គមខ្មែរបច្ចុប្បន្ន ដែលសហចៅក្រុមបានលើកឡើងនោះមិនត្រូវបានទទួលស្គាល់ថាជាការពិតនោះឡើយ។ ក្រុមការពារក្តីយល់ឃើញផងដែរថា ការដែលចាត់ទុកសង្គមកម្ពុជាថាមានលក្ខណៈមិននឹងនរ និងប្រកបដោយអំពើហឹង្សានោះ វាគឺជាទង្វើមួយដែលអាចបង្កនូវផលវិបាកគួរអោយកត់សម្គាល់។

69. ការសិក្សាស្រាវជ្រាវថ្មីៗនេះរបស់កម្មវិធីអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍន៍ (UNDP)[58] និងធនាគារពិភពលោក(World Bank) [59] បានកត់សម្គាល់លើស្ថេរភាពដែលប្រទេសមួយនេះកំពុងជួបប្រទះ[60]។ ការបោះឆ្នោតកាលពីខែកក្កដា ឆ្នាំ២០០៨ លើកចុងក្រោយនេះបានប្រព្រឹត្តទៅក្នុងបរិយាកាសមួយស្ងប់ស្ងាត់ និងគ្មានការប៉ះទង្គិចឬអំពើហឹង្សាណាមួយឡើយ។ ផ្ទុយទៅវិញ វាគឺជាការបោះឆ្នោតគំរូមួយរបស់ប្រទេសនេះ។ លើសពីនេះទៅទៀត ដោយសារមានបញ្ហាទំនាស់មួយដែលទើបកើតឡើងជាមួយប្រទេសថៃទាក់ទងដល់ប្រាសាទព្រះវិហារ យើងឃើញថាគ្មានការប្រើអំពើហឹង្សា ឬការបង្ករចលាចលណាមួយ ដែលត្រូវគួរអោយភ័យខ្លាចនោះឡើយ[61]។

70. នៅក្នុងបរិបទមួយទៀតដែលកើតមានក្រោយជម្លោះ តុលាការអន្តរជាតិជារឿយៗបានអនុញ្ញាតិអោយមានការដោះលែងអោយនៅក្រៅឃុំបណ្តោះអាសន្ននូវជនដែលត្រូវចោទ ទោះបីជាស្ថិតក្នុង

---

[58] របាយការណ៍ស្តីអំពីការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ឆ្នាំ២០០៧៖ " ពាក់ព័ន្ធដល់ជម្រើសរបស់ប្រជាជនតាមជនបទស្រែចម្ការ(RNDH)" ទំព័រ១១៖ " ប្រទេសកម្ពុជាបានជំរុញការអភិវឌ្ឍរបស់ខ្លួនគួរអោយកត់សម្គាល់ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសក្នុងដំនាក់កាលនៃការប្រឈមមុខទៅនឹងវិបត្តិទាំងឡាយដែលបានកើតឡើងរវាងប៉ុន្មានទស្សវត្សចុងក្រោយនេះ។ សន្តិភាព និងស្ថេរភាពត្រូវបានស្ថាបនាឡើងវិញ ហើយដែលទន្ទឹមគ្នានោះវាបានជំរុញអោយ មានការធានាសុវត្ថិភាពដល់សង្គមមនុស្សផងដែរ។ កត្តាខាងលើនេះ រួមផ្សំជាមួយនឹងសក្តានុពលសេដ្ឋកិច្ចក្នុងតំបន់ ក៏ដូចជាពិភពលោកបានជម្រុញអោយមានការកើនឡើងផ្នែកសេដ្ឋកិច្ចក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។"

[59] "ការចែករំលែកធនធាន៖ សមធម៌ និងការអភិវឌ្ឍប្រទេសកម្ពុជា" របាយការណ៍ចុះថ្ងៃទី ១២ មិថុនា ឆ្នាំ២០០៧ នាសន្និសីទរួមមួយរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនិងធនាគារពិភពលោកដែលបានប្រព្រឹត្តទៅនាសណ្ឋាគារអាំងទែរកុងទីណង់តាល់ ភ្នំពេញ/កថាខ័ណ្ឌ ១ និង២៖ " (នាប៉ុន្មានឆ្នាំចុងក្រោយនេះ) ប្រទេសកម្ពុជាបានទទួលនូវការកើនឡើងផ្នែកសេដ្ឋកិច្ចក្នុងកម្រិតមួយខ្ពស់ និងបានកាត់បន្ថយភាពក្រីក្រក្នុងអត្រាគួរអោយកត់សម្គាល់។ (កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ ១៩៩១) បានកំណត់នូវការដំណាក់កាលនៃការចាកចេញពីសង្គ្រាម ឆ្ពោះទៅកាន់សន្តិភាព (...) (ទោះបីជាការពិតសន្តិភាពត្រូវទទួលបានពេញលេញនៅឆ្នាំ ១៩៩៩ ក្រោយការដួលរលំជាស្ថាពរនៃពួកខ្មែរ ក្រហមក៏ដោយ)"។ (បកប្រែក្រៅផ្លូវការ)។

[60] ពាក់ព័ន្ធចំណុចនេះ សូមអាន ពាក្យបណ្តឹងសុំជាបន្ទាន់អោយមានការដោះលែង / កថាខ័ណ្ឌទី ៤៥

[61]ការលើកឡើងពីកុប្បកម្មប្រឆាំងនឹងប្រទេសថៃកាលពីឆ្នាំ២០០៣ គឺមិនមានភាពសមហេតុសមផលសោះ។ កុប្បកម្មនោះគឺស្ថិតក្នុងបរិបទនៃភាពតានតឹងខាងព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ ទាក់ទងដល់តំបន់ប្រាសាទព្រះវិហារ។

កាលៈទេសៈមួយដែលពុំមានស្ថេរភាពក៏ដោយ[62]។ នៅក្នុងតំបន់ដែលជាអតីតយូហ្គោស្លាវី (មានប្រទេសស៊ែរប៊ី ប្រទេសក្រូអាតស៊ី ប្រទេសបូស្នីអែរហ្សេហ្គូវីន និងប្រទេសកូសូវ៉ូ) ជាឧទាហរណ៍ស្រាប់ ភាពតានតឹងបានកើតឡើងដោយសាររឿងក្តីត្រូវបានប្រគល់អោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី ដើម្បីធ្វើការជំនុំជំរះ ហើយដែលករណីនេះមានភាពខុសគ្នាស្រឡះពីករណីរបស់កម្ពុជា។ នាខែមិនា ឆ្នាំ២០០៤ នៅរដ្ឋកូសូវ៉ូ មានចលនាហឹង្សាមួយបានកើតមានឡើងក្នុងផ្ទៃប្រទេសដែលមានអ្នកចូលរួមដល់ទៅជាង ៥១.០០០ នាក់[63]។ ជាការពិត ចលនាដ៏ហឹង្សានេះមិនបានធ្វើអោយអាក់ខានដល់ការដោះលែងលោក Ramush Haradinaj ដែលជាអតីតមេបញ្ជាការកងទ័ពរំដោះរដ្ឋកូសូវ៉ូ អោយនៅក្រៅឃុំបណ្តោះអាសន្នបានឡើយ។ ហេតុផលនៃការចោទប្រកាន់ទៅលើរូបលោក គឺមានការជាប់ទាក់ទងយ៉ាងច្បាស់ទៅនឹងជម្លោះជាតិសាសន៍រវាងជនជាតិស៊ែប នៅកូសូវ៉ូ និងជនជាតិអាល់បានី[64]។

71. ក្រុមមេធាវីការពារក្តីយល់ឃើញថា គ្មានហេតុផលសមស្របណាមួយដែលអាចសន្និដ្ឋានថា មានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដោយសារតែមានការដោះលែងអោយនៅក្រៅឃុំបណ្តោះអាសន្ន ឬក៏ហេតុផលសមស្របណាមួយដែលបង្ហាញថាសណ្តាប់ធ្នាប់សាធារណៈត្រូវបានគម្រាមកំហែងនោះដែរ។

---

[62] សូមមើល៖ TPIY, *ព្រះរាជអាជ្ញា តទល់នឹង Lukic,* IT-98-32/1-AR65.1, ១៦ មេសា ២០០៧/ សេចក្តីសម្រេច ទាក់ទងដល់បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារ ប្តឹងទាស់ទៅនឹងសេចក្តីសម្រេចរបស់សាលាដំបូងពាក់ព័ន្ធនឹងបណ្តឹងសុំ អោយលោក Sredoje Lukic ក្រៅឃុំបណ្តោះអាសន្ន; TPIY, *ព្រះរាជអាជ្ញា តទល់នឹង Galic,* IT-98-20-A, ៣១ តុលា ២០០៥/ សេចក្តីសម្រេចទាក់ទងបណ្តឹង លើកទីពីរសុំអោយនៅ លោក Stanislav Galic ក្រៅឃុំបណ្តោះអាសន្ន; TPIY, *ព្រះរាជអាជ្ញា តទល់នឹង Boskoski,* IT-04-82-AR65.4, ២៧ មេសា ២០០៧/ សេចក្តីសម្រេចទាក់ទងដល់បណ្តឹងសុំ អោយមានការដេញដោលរបស់ Johan Tarculovski ស្តីអំពីការសុំអោយនៅក្រៅឃុំបណ្តោះអាសន្ន។ *ព្រះរាជអាជ្ញា តទល់នឹង Gotovina,* IT-06-90-AR65.1, ១៧ មករា ២០០៨/ សេចក្តីសម្រេចទាក់ទងបណ្តឹងឧទ្ធរណ៍របស់ Ante *Gotovina* ប្តឹងទាស់ទៅនឹងការបដិសេធបណ្តឹងសុំនៅក្រៅឃុំបណ្តោះអាសន្ន។

[63] សូមមើលOSCE “ កូសូវ៉ូ វិបានការណ៍របស់សាលាជំរះក្តីទល់នឹងកុបកម្មនាខែមីនា ឆ្នាំ២០០៤” ខែធ្នូ ឆ្នាំ ២០០៥/ កថាខ័ណ្ឌ ៥ និង ៦។

[64] TPIY, *ព្រះរាជអាជ្ញា តទល់នឹង Haradinaj et al,* IT-04-84-PT, សេចក្តីសម្រេច ទាក់ទង ដល់បណ្តឹងសុំ អោយលោក Ramush Haradinaj ក្រៅឃុំបណ្តោះអាសន្ន / ៦ មិថុនា ឆ្នាំ២០០៥។

00242990



C401511

72. ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តីយល់ឃើញថា ការដោះលែងលោក ខៀវ សំផន អោយនៅក្រៅឃុំ គឺជាសារមួយដែលអាចបញ្ជាក់ពីការគោរពយ៉ាងជាក់ស្តែង នូវគោលការណ៍សច្ចធារណ៍និរទោសទៅវិញទេ[65]។

### ៣) សហចៅក្រមស៊ើបអង្កេត មិនបានសន្និដ្ឋានថា ការសម្រេចដោះលែងលោក ខៀវ សំផន នឹងបណ្តាល អោយមានផលប៉ះពាល់ដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់បុគ្គលនោះឡើយ

73. សហចៅក្រមស៊ើបអង្កេត សន្និដ្ឋានថា វាអាចនឹងកើតមានឡើងនូវការសងសឹកជាលក្ខណៈ បុគ្គល និងគ្រោះថ្នាក់ដែលអាចយាយីដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់ជនដែលត្រូវចោទ៖ ១. នៅក្រោយពេលដែលពាក្យបណ្តឹងជាផ្លូវការត្រូវបានធ្វើឡើង ២. និងក្នុងអំឡុងពេលមួយដោយផ្សាភ្ជាប់ទៅនឹងការផ្សព្វផ្សាយពត៌មានទាក់ទងដល់នីតិវិធី ព្រមទាំងស្ថានភាពជាក់ស្តែងរបស់សង្គម ៣. ព្រមទាំងស្ថានភាពធ្ងន់ធ្ងរនៃទង្វើដែលបានប្រព្រឹត្ត រួមជាមួយនឹងការគម្រាមកំហែង ដល់សណ្តាប់ធ្នាប់សាធារណៈផងដែរ[66]។

74. ជាថ្មីម្តងទៀត ផ្អែកលើផ្លូវច្បាប់ យើងអាចចោទជាសំណួរបានថា តើមានហេតុផល សមស្របដូចម្តេចខ្លះក្នុងការបដិសេធលើពាក្យសុំអោយនៅក្រៅឃុំនោះ ក្រៅអំពីតែហេតុផលដោយសារតែនីតិវិធីជំនុំជំរះកំពុងតែត្រូវបានដំណើរការ ឬត្រូវបានគេធ្វើការ ផ្សព្វផ្សាយនោះ[67]។

75. ជាមួយគ្នានេះដែរ ផ្អែកលើផ្លូវច្បាប់ យើងក៏អាចចោទជាសំណួរពាក់ព័ន្ធដល់ភាពសមហេតុផលនៃការលើកឡើងពីកត្តានៃការវាយតម្លៃស្ថានភាពមួយ ដើម្បីកំណត់អំពីផលវិបាករបស់វា ដែលអាចជះឥទ្ធិពលដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់បុគ្គលជនដែលត្រូវចោទ ឬទៅលើហេតុផលនានាដែលពាក់ព័ន្ធដល់ទស្សនាទានរបស់សង្គមនោះ។

76. ទាក់ទងដល់បញ្ហានេះ វាពិតប្រាកដណាស់ដែលថា រាល់បណ្តឹងទាំងឡាយដែលប្តឹងមកអង្គជំនុំជម្រះវិសាមញ្ញបានជម្រុញអោយមានការលុបបំបាត់ចោលនូវទម្រង់នៃនិទណ្ឌភាពមួយចំនួន និងប្រឆាំងតបរាល់ការសងសឹកជាលក្ខណៈបុគ្គលទាំងឡាយដែលមានឆន្ទៈមិនច្បាស់លាស់ និងដើម្បីស្របតាមវិញ្ញាណរបស់យុត្តិធម៌។

---

[65] បណ្តឹងបន្ទាន់សុំនៅក្រៅឃុំ / កថាខ័ណ្ឌ ៥០។

[66] ដីកាសម្រេចបដិសេធន៍ដាក់ឲ្យនៅក្រៅឃុំ កថាខណ្ឌទី ២១ និង ២២។

[67] ត្រង់ចំនុចនេះ យើងនឹងធ្វើការកត់សំគាល់ជាថ្មីម្តងទៀត ច្បាប់បារាំងចុះថ្ងៃទី ៥ មីនា ២០០៧ ចែងថា "ការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈមិនមែនកើតចេញមកតែពីការលេចឮខ្ទរខ្ទារនូវពត៌មានស្តីពីរឿងក្តីនោះមួយឡើយ" ។

77. លើសពីនេះទៅទៀតទាំងចារឹកលក្ខណៈធ្ងន់ធ្ងរនៃអង្គហេតុ ទាំងការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ (ហើយជាពិសេសនៅពេលដែលលក្ខណៈវិនិច្ឆ័យមិនត្រូវបានគេបង្ហាញ) មិនអាចត្រូវបានចាត់ទុកថា ជាមូលហេតុសមស្របមួយដែលបណ្តាលអោយមាន ការគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់បុគ្គលឡើយ។

78. ជាទីបញ្ចប់ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា យើងត្រូវបំភ្លេចនូវស្ថានភាពដែលថា "លោក ខៀវ សំផន ធ្លាប់បានរស់នៅដោយសេរីអស់រយៈពេលជាងសាមសិបឆ្នាំ ដោយមិនបានប្រឈមមុខទៅនឹងហេតុការណ៍អាក្រក់ណាមួយ ដែលប៉ះពាល់ដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ឡើយ។ ក្នុងពេលជាមួយគ្នានោះដែរ ទោះបីជាសហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា "ព្រឹត្តិការណ៍កាលពីឆ្នាំ១៩៩១ ដែលនៅពេលនោះ លោក ខៀវ សំផន ត្រូវបានចោមរោមដេញតាម និងវាយបែកក្បាលដោយហ្វូងមហាជនដែលខឹងសម្បារយ៉ាងខ្លាំងនោះ (ប៉ុន្តែហេតុការណ៍នេះ) មិនអាចចាត់ទុកជាភយន្តរាយសម្រាប់ពេលបច្ចុប្បន្ននេះឡើយ"។ សហចៅក្រមស៊ើបអង្កេតក៏បានចាត់ទុកផងដែរថា ព្រឹត្តិការណ៍អស់ទាំងនោះ"បានបន្ថែមនូវគុណប្រយោជន៍ដល់និក្ខេបបទដែលបានបកស្រាយខាងលើ ហើយក៏គ្មានអ្វីមួយអាចទប់ស្កាត់មិនអោយព្រឹត្តិការណ៍ណាមួយកើតឡើងបានផងដែរ"[68]។

79. សហចៅក្រមស៊ើបអង្កេត បានលើកយកព្រឹត្តិការណ៍ដ៏ចំណាស់ដែលបានកើតឡើងតាំងពី១៥ឆ្នាំមុនម្ល៉េះ ហើយដែលព្រឹត្តិការណ៍នោះបានកើតឡើងក្នុងអំឡុងពេលដែលកម្ពុជាកំពុងមានវិបត្តិផ្នែកនយោបាយ[69] មកធ្វើជាអំណះអំណាងដើម្បីសន្និដ្ឋានភយន្តរាយដែលអាចកើតមានលើសុវត្ថិភាពផ្ទាល់ខ្លួនរបស់លោក ខៀវ សំផន ដែលនេះពុំមានលក្ខណៈត្រឹមត្រូវនោះឡើយ។ ក្រុមមេធាវីការពារក្តីចង់បញ្ជាក់ឡើងវិញថា "ការឃុំខ្លួនពុំមែនជា(...)មធ្យោបាយសម្រាប់ការពារសុវត្ថិភាពបុគ្គលម្នាក់ ដែលជាឧទាហរណ៍ត្រូវបានប្តឹងយ៉ាងអយុត្តិធម៌ ដោយក្រុមមហាជន (...) ហើយវាក៏មានការលំបាកផងដែរក្នុងការពន្យល់មនុស្សម្នាក់ថា យើងនឹងឃុំខ្លួនគាត់ដើម្បី "សុវត្ថិភាពរបស់គាត់" ទន្ទឹមគ្នានឹងពេលដែលជននោះបានស្នើអោយមានវិធានការណ៍ផ្សេងពីការឃុំខ្លួននេះ[70]។

---

[68] ដីកាបដិសេធន៍ដាក់ឲ្យនៅក្រៅឃុំ កថាខណ្ឌទី២១។

[69] បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសអំពើសាហាវយង់ឃ្នងដែលបានប្រព្រឹត្តិក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ បានត្រូវបកអាក្រាតយ៉ាងពេញទំហឹង និងភាពស្រឡាំងកាំងក៏បានកើតឡើង ដោយអ្នកខ្លះត្រូវទទួលរងការរិះគន់ផងដែរ។

[70] CHAMBON (P.), GUERY (C.), Droit et pratique de l'instruction préparatoire, Dalloz Action 2007/2008, កថាខ័ណ្ឌទី ១៤២.៧៤

80. ភយន្តរាយដែលសហចៅក្រមស៊ើបអង្កេតបានខ្វល់ខ្វាយថានឹងអាចកើតឡើងនោះ មានលក្ខណៈពុំជាក់ស្តែង និងពុំមានភាពបច្ចុប្បន្ន។ ភយន្តរាយនោះគ្រាន់ស្ថិតក្នុងការសន្មត់ និងមានចារឹតលក្ខណៈជាសម្មតិកម្មមួយតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ វាពុំមានហេតុផលសមស្របដើម្បីអាចបដិសេធចោលការសុំអោយដោះលែងលោក ខៀវ សំផន ពីការឃុំខ្លួនបណ្តោះអាសន្នឡើយ។

## គ. ការដោះលែងអោយនៅក្រៅឃុំគឺជាសេចក្តីសម្រេចតែមួយគត់ដែលឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង

81. ការឃុំខ្លួនបណ្តោះអាសន្នដោយសារវាត្រូវបានគេសម្រេចមុនពេលធ្វើការចោទប្រកាន់ជនណាម្នាក់ វាគឺជាទម្រង់នៃការធ្វើសេចក្តីសម្រេចបឋមមួយដែលបានប៉ះពាល់ (ទោះបីជាត្រូវបានអនុញ្ញាតិដោយច្បាប់ក្តី) ដល់គោលការណ៍សច្ចធារណ៍និរទោស។ សម្រាប់ជនជាប់ឃុំ ការដែលខ្លួនត្រូវបានគេឃុំជារៀងរាល់ថ្ងៃ វាគឺជាភយន្តរាយមួយរួចស្រាច់ទៅហើយ ទោះបីជាក្នុងករណីដែលជននោះត្រូវបានរកឃើញនូវចុងបញ្ចប់ថាគ្មានទោស និងទទួលបាននូវការសងសំណងជម្ងឺចិត្តក៏ដោយ ក៏ការរំលោភបំពានលើសេចក្តីថ្លៃថ្នូរ និងសេរីភាពរបស់បុគ្គលនោះ ត្រូវបានប្រព្រឹត្តរួចមកហើយដែរ។ យោងទៅលើហេតុផលនេះហើយដែលជាគោលការណ៍ គួរដោះលែងជនដែលត្រូវចោទ។

82. ដោយយោងលើកាលៈទេសៈជាក់ស្តែង និងយោងលើគោលការណ៍ដែលថា លោក ខៀវ សំផន ត្រូវបានសន្មត់ជាមុនថាគ្មានទោសនូវរាល់បទល្មើសទាំងឡាយដែលគេបានចោទប្រកាន់មកលើគាត់ យើងអាចចោទជាសំណួរថា តើមានហេតុផលស្របច្បាប់ណាមួយដែលចាំបាច់តម្រូវ អោយមានការឃុំខ្លួនលោក ខៀវ សំផន ក្រៅតែអំពីហេតុផលដែលទាក់ទងដល់ស្ថានភាពធ្ងន់ធ្ងរនៃបទល្មើសដែលបានចោទប្រកាន់លើរូបគាត់ដែរឬទេ? ចម្លើយគឺគ្មាន។

***ការឃុំខ្លួនលោក ខៀវ សំផន គឺធ្វើឡើងដោយបំពាន***

83. សំណើសុំជាបន្ទាន់អោយមានការដោះលែង ដែលបានដាក់ជូនសហចៅក្រមស៊ើបអង្កេត ព្រមទាំងសារណាឧទ្ធរណ៍នេះបានផ្អែកលើភាពពុំចាំបាច់នៃការឃុំខ្លួន។ ទឡ្ហីករណ៍អស់ទាំងនេះត្រូវបានលើកឡើងដោយពុំមានសារប្រយោជន៏អ្វីទាំងអស់។ ជាក់ស្តែង សហមេធាវីការពារក្តីយល់ឃើញថា ការឃុំខ្លួនលោក ខៀវ សំផន ត្រូវបានធ្វើឡើងក្នុងដំណាក់កាលនៃនីតិវិធីពុំសមស្រប ហើយដែលការឃុំខ្លួននេះនឹងបន្តបង្កើតអនុភាពខុសច្បាប់ថែមទៀតផង។ ដូច្នេះ ការឃុំខ្លួននេះត្រូវបានធ្វើឡើងដោយបំពាន ហើយ លោក ខៀវ សំផន ត្រូវតែទទួលបាននូវការដោះលែង។

***ការឃុំខ្លួនលោក ខៀវ សំផន បានអូសបន្លាយពេលលើសពីមួយឆ្នាំទៅហើយ***

84. សហចៅក្រមស៊ើបអង្កេត បានសន្និដ្ឋានថា " រយៈពេលដែលកន្លងទៅនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនត្រូវបានចាត់ថាមិនត្រូវត្រូវទេ ប្រសិនបើមានភស្តុតាងបង្ហាញថា នីតិវិធីប្រព្រឹត្តទៅប្រកប ដោយការយកចិត្តទុកដាក់[71]"មិនត្រឹមតែប៉ុណ្ណោះ សហចៅក្រមស៊ើបអង្កេត បានបន្ថែមទៀតថា "សិទ្ធិនៅស្ងៀមត្រូវបានគេទទួលស្គាល់ និងមិនអាចជំទាស់បាន ប៉ុន្តែសិទ្ធិនេះមិនរួមចំណែកក្នុង ការជំរុញនីតិវិធីអោយប្រព្រឹត្តទៅលឿនឡើយ"[72]។

85. ចំពោះចំណុចនេះ សហមេធាវីសូមរំលឹកថា ខ្លួនបានលើកឡើងយ៉ាងច្បាស់រួចមកហើយអំពីកង្វះ ខាតនៃការយកចិត្តទុកដាក់នៅក្នុងដំណើរការនៃនីតិវិធី ហើយលោក ខៀវ សំផន មិនបានជ្រើស រើសអនុវត្តសិទ្ធិក្នុងការរក្សាការស្ងាត់ស្ងៀមនោះទេគឺគ្រាន់តែគាត់នៅស្ងាត់ស្ងៀមដោយសារមេធាវី របស់គាត់មិនបានទទួលសំណុំរឿងស៊ើបអង្កេតគ្រប់គ្រាន់។

***លោក ខៀវ សំផន មានវ័យចាស់ជរា ហើយសុខភាពរបស់គាត់ទន់ខ្សោយ***

86. ក្រុមមេធាវីការពារក្តីមិនយល់ថាស្ថានភាពសុខភាពរបស់លោក ខៀវ សំផន មានវិសមិតភាពជា មួយនឹងការឃុំខ្លួន តែយល់ថា វិធានការនេះអាចធ្វើឲ្យគាត់ចុះខ្សោយ ហើយចុងក្រោយធ្វើអាចធ្វើ ឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់គាត់។ លោក ខៀវ សំផន ឋិតក្នុងស្ថានភាពល្អ ប៉ុន្តែផលវិបាក នៃគ្រោះថ្នាក់ដាច់សរសៃខួរក្បាលនៅតែមានវត្តមាន៖ ដូចជាភាពមិនមានលំនឹងនៃការដើរ មាន រ៉េផ្លិចយឺត ពិបាកក្នុងការនិយាយ និងមានការគិតយឺត។ ក្រុមគ្រូពេទ្យក៏បានឯកភាពគ្នាដែរថា "គ្រោះថ្នាក់ដាច់សរសៃឈាមខួរក្បាលនៅតែអាចកើតមាន[73]"។ យើងមិនអាចព្រងើយកន្តើយ ចំពោះបញ្ហានេះបានទេ។

***គ្មានអ្វីដែលជំទាស់ដល់ការដោះលែងលោក ខៀវ សំផន ឲ្យមានសេរីភាពនោះទេ***

ដូចមានបញ្ជាក់នៅក្នុងផ្នែកទីពីរ(ខ) នៃសារណានេះរួចមកហើយ គឺគ្មានអ្វីដែលជំទាស់ដល់ការ ដោះលែងលោក ខៀវ សំផន ឲ្យមានសេរីភាពនោះទេ។

---

[71] ដីកាបដិសេធន៍ដាក់ឲ្យនៅក្រៅឃុំ កថាខណ្ឌទី២៧។

[72] ដីកាបដិសេធន៍ដាក់ឲ្យនៅក្រៅឃុំ កថាខណ្ឌទី២៩។

[73] ដីកាបង្គាប់ឲ្យមានការធ្វើកោសល្យវិច្ច័យ លើលោក ខៀវ សំផន ថ្ងៃទី០៦ តុលា ២០០៨ និងរបាយការណ៍កោសល្យវិច្ច័យ ចុះថ្ងៃទី ២៧ តុលា ២០០៨ *ឯកសារតុលាការ B/13 និង B13/1* ។

## IV. ហេតុដូចនេះ

87. សហមេធាវីការពារក្តី សូមស្នើអោយអង្គបុរេជំនុំជំរះមេត្តាៈ

- **បដិសេធចោល**នូវដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធពាក្យសុំនៅក្រៅឃុំបណ្តោះអាសន្ន ដែលចេញដោយសហចៅក្រមស៊ើបអង្កេត
- **បង្គាប់អោយមានការដោះលែងលោក ខៀវ សំផន**

ជំនួសសហមេធាវីទាំងពីរ

លោកមេធាវី ស សូវាន